ព្រឹត្តិបត្រប្រចាំខែ

*Monthly Newsletter*

# ការអប់រំ និង បច្ចេកវិទ្យា

# Education & Technology

ឆ្នាំទី១ លេខ00១ ចេញផ្សាយប្រចាំខែមករា-មេសា ឆ្នាំ២0២១

Android iOS

Android iOS

ការិយាល័យ: សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

ប្រអប់សំបុត្រ: P.O Box ១៦២១ ភ្នំពេញ កម្ពុជា 042-941-481 / 042-941-918

kape@kapekh.org www.kapekh.org Find us on Facebook www.facebook.com/kapeaction

YouTube www.youtube.com/TheKapeCambodia LinkedIn www.linkedin.com/in/kapecambodia/

Follow us on twitter www.twitter.com/KAPECambodia

# មាតិកា


អំពីអង្គការ ខេប ចំនួនគម្រោងកំពុងប្រតិបត្តិ និងម្ចាស់ជំនួយក្នុងឆ្នាំ២០២១ ........................ ១-២


## ការអភិវឌ្ឍសាលារៀនជំនាន់ថ្មី (NGS)


ការតម្រង់ទិសសិស្សអំពីកម្មវិធីប្រឹក្សាអាជីព ........................ ៣

សិក្ខាសាលាមូលដ្ឋានស្តីពី "**ការបំប៉នសមត្ថភាពគ្រូថ្មី**" ........................ ៤

កម្មវិធីសាលារៀនជំនាន់ថ្មីបានរៀបចំកម្មវិធីអង្គវិបស្សនាប្រចាំឆ្នាំ២០២១ ........................ ៥

សិក្ខាសាលាស្តីពី "វិទ្យាសាស្ត្រ" ........................ ៦


## ព័ត៌មានវិទ្យា ទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់ការអប់រំ


ការប្រើប្រាស់ឧបករណ៍វាយតម្លៃចុងឆ្នាំសិក្សា ........................ ៧

គម្រោងកុមារកម្ពុជារីករាយចុះធ្វើតេស្តវាយតម្លៃអំណានថ្នាក់ដំបូង ........................ ៧

ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការសិក្សា ប្រជុំ និងទំនាក់ទំនងគ្រួសារក្នុងបរិបទជំងឺកូវីដ-១៩ ........................ ៨

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលថ្នាក់ជាតិនៃកម្មវិធីសាលារៀនជំនាន់ថ្មី ........................ ៨

សេចក្តីណែនាំក្រសួងអប់រំឱ្យអនុវត្តកម្មវិធីត្រីវិស័យនៅមធ្យមសិក្សា ........................ ៩


## ការអភិវឌ្ឍគ្រូបង្រៀន


អត្ថប្រយោជន៍ការវគ្គបំប៉នសមត្ថភាពបង្រៀនដល់គ្រូកិច្ចសន្យា ........................ ១០


## កម្មវិធីអប់រំបរិយាប័ន្ន


ខ្មែរបរិបទនីយកម្មមេរៀនបំណិនជីវិតចំនួន៨ក្បាល ........................ ១១

ប្រសិនបើអ្នកចង់ឱ្យគេជួយ លុះត្រាអ្នកត្រូវខិតខំប្រឹងប្រែងតស៊ូគ្រប់បែបយ៉ាងជួយខ្លួនឯងឱ្យអស់ពីលទ្ធភាព ជាមុនសិន ........................ ១២

តួនាទីស្ត្រីក្នុងវិស័យឯកជន ........................ ១៣

នាងខ្ញុំជាស្ត្រីមូស្លីមមានឱកាសបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា ........................ ១៤

ស្ត្រីជនបទជោគជ័យលើការសិក្សានៅកម្រិតថ្នាក់ឧត្តមសិក្សា ........................ ១៤


## កម្មវិធីអំណានថ្នាក់ដំបូង


ទិវាជាតិអំណាន ១១មីនា ២០២១ ........................ ១៥


## កម្មវិធីមត្តេយ្យសិក្សា


បច្ចេកទេសបង្រៀនមត្តេយ្យជំនាន់ថ្មី ........................ ១៦

ការកែលម្អមត្តេយ្យជំនាន់ថ្មី ........................ ១៧


## រចនាបថហេដ្ឋារចនាសម្ព័ន្ធ


ការវិនិយោគរបស់ ខេប ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ........................ ១៨

ការផ្លាស់ប្តូរវិជ្ជមានរបស់លោកនាយក និងគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាឈើខ្លឹម ........................ ១៩


## ការអភិវឌ្ឍបណ្ណាល័យ


ពង្រឹងបណ្ណាល័យស្តង់ដាសតវត្សរ៍ទី២១ ........................ ២១

កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់គម្រោងសៀវភៅសម្រាប់កម្ពុជា (BFC)..........២១

## កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

សិក្ខាសាលាស្ដីពី "**ការអប់រំបំណិនជីវិតមូលដ្ឋាន**"..........២២

## កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩

យើងធ្វើការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពសម្រាប់កិច្ចគាំទ្រចំពោះបញ្ហាប្រឈមលើការសិក្សារបស់សិស្សកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩..........២៣
ការជំរុញសិស្សានុសិស្សបន្តអនុវត្តន៍ការសិក្សាពីចម្ងាយ (បែបនិម្មិត)..........២៥

## ព្រឹត្តិការណ៍ ការស្រាវជ្រាវចំណេះដឹង និងការកំសាន្តផ្សេងៗ

បុគ្គលិករបស់ធនាគារ អេប៊ីអេ (ABA) បានឧបត្ថម្ភដបដាក់ទឹកដល់អង្គការ ខេប..........២៦
កិច្ចប្រជុំប្រចាំខែរបស់គម្រោងកុមារកម្ពុជារីករាយ (HCC)..........២៦
កុំអស់សង្ឃឹម!..........២៧
ចុងក្រោយអ្នកត្រូវធ្វើការសម្រេចចិត្ត..........២៧
តម្លៃនៃអំណាន..........២៨
មតិអ្នកអាន..........២៨
វិធានការ ៣កុំ ៣ការពារ..........២៩
យថាគ្រោះណាស់បើកូនគ្មាន!..........៣០
សារលើកទឹកចិត្ត..........៣០


# ព្រឹត្តិបត្រ "ការអប់រំ និងបច្ចេកវិទ្យា"
## រៀបចំផលិត និងចេញផ្សាយដោយ

| | | |
|---|---|---|
| លោក អឿ សាវីន | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ | រៀបចំផែនការ បង្កើតទម្រង់ និងរចនា |
| លោក ឈួន តារា | មន្ត្រីបច្ចេកវិទ្យាព័ត៌មានជាន់ខ្ពស់ | ជំនួយការបច្ចេកទេស |
| លោក ខ៊ាន់ សុខសារៈ | មន្ត្រីតាមដាន & វាយតម្លៃ និងគ្រប់គ្រងទិន្នន័យជាន់ខ្ពស់ | ជំនួយការផ្នែកទិន្នន័យ |
| លោក ម៉ៃ សុខឃា | មន្ត្រីព័ត៌មានវិទ្យា | ជំនួយការបច្ចេកទេស |
| កញ្ញា ជ្រុន ភាត់ថា | ជំនួយការផ្នែកទំនាក់ទំនង | ប្រមូល និងសរសេរព័ត៌មាន |

## ត្រួតពិនិត្យ និងកែសម្រួលខ្លឹមសារដោយ

| | |
|---|---|
| លោក ឆន នៃយុទ្ធ | ប្រធានសម្របសម្រួលផ្នែកបច្ចេកវិទ្យាសម្រាប់ការអប់រំ |
| លោក ពេជ្រ សុភឿន | ប្រធានគម្រោងសៀវភៅសម្រាប់កម្ពុជា |
| កញ្ញា ស៊ឹម ផល្លី | ប្រធានក្រុម |

# អំពីអង្គការ ខេប

ខេប គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១៥០០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ដែលបង្រៀននៅជាង ៤០០សាលាក្នុង១៣រាជធានី-ខេត្ត។

### ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

### បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនងាយរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

### គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី ឬច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

## មុខងារគម្រោងរបស់អង្គការ ខេប តាមផ្នែកបច្ចេកទេសក្នុងឆ្នាំ២០២១

| គម្រោងខេបក្នុងឆ្នាំ២០២១ | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាប័ន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមត្តេយ្យសិក្សា | វចនាបថហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍបណ្ណាល័យ | កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព | កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១. គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC) | BfC | | | | | | | | ✓ | | |
| ២. កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ-១៩ | CERRP | | ✓ | ✓ | ✓ | ✓ | | | | | ✓ |
| ៣. គម្រោងអប់រំកុមារី | GEI | | | | ✓ | | | | | ✓ | ✓ |
| ៤. គម្រោង វាយតម្លៃ-**GPE3** (តេស្ត **EGRA**) | GPE3-PE | | | | | ✓ | | | | | |
| ៥. គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. គម្រោង សកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា | KYLA | | | | ✓ | | | | | ✓ | |
| ៧. គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ | |
| ៨. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | | | | | | | ✓ |
| ៩. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតបឋម) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ |
| ១០. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតមធ្យម) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១១. គម្រោង សាលារៀនជំនាន់ថ្មី/ស្វាយរៀង | NGS-SR | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១២. គម្រោង ពន្លកចំណេះ (ស្រាវជ្រាវប្រឹក្សាគរុកោសល្យ) | PC | | | ✓ | | | | | | | |
| ១៣. គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACH IV | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៤. គម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | SEEK | | | ✓ | ✓ | | | | | ✓ | ✓ |
| ១៥. គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ | TRAC III | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | ✓ |
| ១៦. គម្រោង អភិវឌ្ឍន៍វិស័យអប់រំ-មធ្យមសិក្សា ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ | |
| ១៧. គម្រោង សហគ្រិនវ័យក្មេង | YEP | | | | ✓ | | | | | ✓ | ✓ |
| **សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ** | | ៤ | ៧ | ១១ | ១២ | ៦ | ៣ | ៦ | ៨ | ១១ | ១២ |

# ម្ចាស់ជំនួយអង្គការ ខេប ក្នុងឆ្នាំ២០២១

ក្រសួងអប់រំ យុវជន និងកីឡា

Happy Cambodian Children Org.

unicef for every child

GPE Transforming Education

GVC

WeWorld

This project is co-funded by the European Union

علم طفلاً EDUCATE A CHILD — A programme of education above all

Aide et Action — Changing the world through Education

THE PHOENIX FOUNDATION

ChildFund Cambodia

ADB

The Asia Foundation — Improving Lives, Expanding Opportunities

OXFAM

lotus outreach INTERNATIONAL

lotus outreach SOCIETY CANADA

USAID FROM THE AMERICAN PEOPLE

pact building local promise.

Oaktree

UNESCO

Gap Inc.

P.A.C.E. Gap Inc. Advancing Women to Advance the World

FFF | Franks Family Foundation



គម្រោងកុមារកម្ពុជារីករាយ "ពង្រឹងសកម្មភាពអំណានថ្នាក់ដំបូងរបស់កុមារ និងការកែលម្អសមត្ថភាពគ្រប់គ្រងដៃគូនៅមូលដ្ឋាន ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាអប់រំ និងគុណភាពបង្រៀន និងរៀន ជាពិសេសសម្រាប់កុមាររៀនថ្នាក់ទី១, ២ និងទី៣"។




# ការតម្រង់ទិសសិស្សអំពីកម្មវិធីប្រឹក្សាអាជីព


កម្មវិធីប្រឹក្សាអាជីព វិទ្យាល័យ ហ៊ុន សែន ពាមជីកង


កម្មវិធីប្រឹក្សាអាជីព វិទ្យាល័យព្រែកលៀប


កម្មវិធីប្រឹក្សាអាជីព វិទ្យាល័យហ៊ុន សែន កំពង់ចាម


កម្មវិធីប្រឹក្សាអាជីព វិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិ
សាលជាស៊ីមព្រែកអញ្ចាញ

កម្មវិធីសាលារៀនជំនាន់ថ្មី បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពី "ការតម្រង់ទិសសិស្សអំពីកម្មវិធីប្រឹក្សាអាជីព" កាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១ នៅសាលប្រជុំវិទ្យាល័យ ហ៊ុន សែន កំពង់ចាម។ កម្មវិធីតម្រង់ទិសអាជីពនេះមានគោលបំណងណែនាំសិស្សានុសិស្សយល់ដឹងអំពីការផ្តល់សេវាកម្មរបស់កម្មវិធី ព្រមទាំងធ្វើបទបង្ហាញពីរបៀបកំណត់គោលដៅទៅដល់សិស្សានុសិស្ស។ អ្នកចូលរួមសរុបមានចំនួន ៨៦នាក់ រួមមានៈ គ្រូប្រឹក្សាអាជីព បុគ្គលិកអង្គការ ខេប និងសិស្សថ្នាក់ទី៧នៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដែលបានប្រព្រឹត្តទៅក្រោមបរិយាកាសរីករាយដោយមានការយកចិត្តទុកដាក់ខ្ពស់។

កម្មវិធីតម្រង់ទិសអាជីពនេះត្រូវបានធ្វើឡើងគ្រប់សាលារៀនជំនាន់ថ្មីទាំងអស់។ ដូច្នេះ សិស្សានុសិស្សបានស្វែងយល់បន្ថែមអំពីកម្មវិធីប្រឹក្សាអាជីព ទទួលបានចំណេះដឹងច្រើនទាក់ទងនឹងការកំណត់គោលដៅ ជាពិសេសបានសិក្សាស៊ីជម្រៅអំពីសេវាកម្មផ្តល់ប្រឹក្សាអាជីពតាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រើប្រាស់កម្មវិធីត្រីវិស័យជ្រើសរើសជំនាញឱ្យត្រូវនឹងចំណង់ចំណូលចិត្តរបស់ខ្លួនបន្ទាប់ពីបញ្ចប់ការសិក្សាពីវិទ្យាល័យទៅ។

ជាលទ្ធផល សិស្សានុសិស្សបានរៀនសូត្រនូវអ្វីដែលហៅថាប្រឹក្សាអាជីព រួមទាំងចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនជាច្រើន ហើយធ្វើការរៀបចំផែនការ និងគោលដៅសម្រាប់ជីវិត ដោយពួកគាត់សួរខ្លួនឯងថាពួកគេចង់ក្លាយជាអ្វីនាពេលខាងមុខ និងដឹងថាពួកគេអាចរកអ្នកប្រឹក្សាយោបល់បាននៅពេលពួកគេពិបាកក្នុងការសម្រេចចិត្តក្នុងការធ្វើអ្វីមួយ។





# សិក្ខាសាលាមូលដ្ឋានស្តីពី "ការបំប៉នសមត្ថភាពគ្រូថ្មី"



*សកម្មភាពលោកគ្រូអ្នកគ្រូកំពុងពិភាក្សាគ្នាអំពីវិធីសាស្ត្របង្រៀន និងរៀនដើម្បីផ្ទេរទៅសិស្ស ប្រកបដោយប្រសិទ្ធភាព*

កម្មវិធីសាលារៀនជំនាន់ថ្មី-ស្វាយរៀង ក្រោមការគាំទ្រហិរញ្ញប្បទានពីអង្គការឆាល ហ្វានកម្ពុជា និងប្រតិបត្តិដោយអង្គការ ខេប បានរៀបចំសិក្ខាសាលាមូលដ្ឋានស្តីពី "ការបំប៉នសមត្ថភាពគ្រូថ្មី" នៅវិទ្យាល័យគោកព្រីង កាលពីថ្ងៃទី២៨ ខែមករា ដល់ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ មានរយៈពេល ៩ថ្ងៃ ដែលមានសិក្ខាកាមចូលរួមសរុបជាង៥០នាក់ មកពីវិទ្យាល័យគោកព្រីង និងបឋមសិក្សាស្វាយព្រហ៊ុត។ សិក្ខាសាលានេះមានគោលបំណងបំប៉នវិធីសាស្ត្របង្រៀនថ្មីៗ និងណែនាំអំពីគោលនយោបាយ ព្រមទាំងគោលការណ៍ប្រតិបត្តិនៅក្នុងសាលារៀនជំនាន់ថ្មី ជាពិសេសបានផ្តល់ចំណេះដឹងដូចខាងក្រោម៖

១)-ការអប់រំនៅសតវត្សរ៍ទី២១ គឺជាចលនាឆ្ពោះទៅរកវិធីសាស្ត្របង្រៀនថ្មីៗ ដូចជា វិធីសាស្ត្របង្រៀនបែបរិះរក វិធីសាស្ត្របង្រៀនអាស្រ័យលើបញ្ហាត្រូវបានជំរុញយ៉ាងខ្លាំងដោយការផ្លាស់ប្តូរសេដ្ឋកិច្ចក្នុងសតវត្សរ៍ទី២១។

២)-ការយល់ដឹងអំពីការកែទម្រង់ដំណើរការបង្រៀន និងរៀននៅកម្ពុជា។

៣)-ការសិក្សាបែបស្ថាបនានិយមជាទិដ្ឋភាពដែលសិស្សសហការគ្នា កសាងចំណេះដឹងចេញពីបទពិសោធន៍ និងការគិតរបស់ពួកគាត់ម្នាក់ៗ។ តាមរយៈបទពិសោធន៍ទាំងនេះ ពួកគាត់អាចធ្វើការឆ្លុះបញ្ចាំងដើម្បីបង្កើតគំនិត ឬបញ្ញត្តិថ្មីៗ។ យុទ្ធសាស្ត្របង្រៀនសំខាន់ៗក្នុងការសិក្សាបែបស្ថាបនានិយមមាន ដូចជា វិធីសាស្ត្រសិក្សាបែបសហការ វិធីសាស្ត្រធ្វើគម្រោងសិក្សា វិធីសាស្ត្រសិក្សាអាស្រ័យលើគម្រោង វិធីសាស្ត្របែបរិះរក វិធីសាស្ត្រដោះស្រាយបញ្ហា វិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហា វិធីបង្រៀនបែបតុក្កតាគំនិត និងការផ្សារភ្ជាប់ការសិក្សាបែបស្ថាបនានិយម និង Bloom's Taxonomy។

៤)-ការកំណត់វត្ថុបំណង និងការតែងតេស្ត គឺការធ្វើតេស្តអំពីការវាយតម្លៃ ការសរសេរវត្ថុបំណងមេរៀន ការបង្កើតតេស្តដែលមានសុពលភាពដែលទាក់ទងជាមួយវត្ថុបំណងមេរៀន និងការប្រើប្រាស់តារាងផែនការតេស្ត។

៥)-ការបង្រៀនតាម តម្រូវការសិស្ស ផលអាក្រក់នៃការដាក់ស្លាកសិស្ស

៦)-ជំនាញក្នុងការគ្រប់គ្រងថ្នាក់រៀន

៧)-ការសិក្សាបែបសហការ គឺជាការអនុវត្តការបង្រៀនដែលផ្តល់ឱកាសឱ្យសិស្សរៀនរួមគ្នាជាក្រុមតូច។ មូលហេតុសំខាន់ៗនាំឱ្យមានការសិក្សាអំពីវិធីសាស្ត្រការសិក្សាបែបសហការគឺសិស្សភាគច្រើនសិក្សាយ៉ាងសកម្ម សិស្សរៀនជួយគ្នាទៅវិញទៅមក ការគាំទ្របែបបណ្តាញកុមារជួយកុមារ និងកម្លាំងទឹកចិត្តកើនឡើងតាមរយៈភាពជោគជ័យ។

៨)-ក្របខណ្ឌអភិវឌ្ឍន៍គ្រូបង្រៀនមានចំណុចសំខាន់ ដូចជា ការអភិវឌ្ឍសំណុំឯកសារគ្រូបង្រៀន ផែនការគន្លងអាជីពគ្រូបង្រៀន ការធ្វើផែនការ និងការអនុវត្ត ការផ្តល់ប្រឹក្សាទល់មុខ ការសង្កេតការបង្រៀន និងការបង្រៀនជាក្រុម សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន ដំណើរទស្សនកិច្ចសិក្សាក្រៅសាលា ឱកាសទទួលបានការអភិវឌ្ឍសមត្ថភាពបន្ថែម ការបង្រៀនបែបឆ្លុះបញ្ចាំង

៩)-ការគ្រប់គ្រងថ្នាក់រៀនអេឡិចត្រូនិកតាមរយៈ កម្មវិធី Google Classroom

១០)-ដឹកនាំការពិសោធន៍តាមមេរៀន និងផលិតសម្ភារៈបង្រៀនតាមមុខវិជ្ជានីមួយៗ ដែលត្រូវពិសោធន៍ដោយរៀបចំផែនការពិសោធន៍និងវិធីសាស្ត្រពិសោធន៍ងាយៗ។

ការបំប៉នសមត្ថភាពគ្រូថ្មីនេះពិតជាបានផ្តល់នូវឱកាសឱ្យលោកគ្រូអ្នកគ្រូបង្រៀនពង្រឹងវិធីសាស្ត្រផ្ទេរចំណេះដឹងទៅសិស្សប្រកបដោយប្រសិទ្ធភាព និងបង្កនូវភាពងាយស្រួលសម្រាប់សិស្សសិក្សាតាមបែបសហការស្ថាបនា និងការច្នៃប្រឌិតថ្មីៗ។ វាក៏បានឆ្លុះបញ្ចាំងអំពីចំណុចខ្វះខាត និងបទពិសោធន៍ល្អៗជាច្រើនយកទៅចូលរួមអភិវឌ្ឍន៍វិស័យអប់រំនៅក្នុងប្រទេសកម្ពុជាប្រកបដោយ ចីរភាព៕





# កម្មវិធីសាលារៀនជំនាន់ថ្មីបានរៀបចំអង្គវិបស្សនាប្រចាំឆ្នាំ២០២១

កម្មវិធីសាលារៀនជំនាន់ថ្មី ក្រោមជំនួយហិរញ្ញប្បទានពីក្រសួងអប់រំ យុវ ជន និងកីឡា បានរៀបចំ "អង្គវិបស្សនាប្រចាំឆ្នាំ" នាថ្ងៃទី១៦-២០ ខែកុម្ភៈ ឆ្នាំ២០២១ នៅរមណីយដ្ឋានបក្សីមេគង្គ ស្ថិតក្នុងខេត្តស្ទឹងត្រែងដោយមានមន្ត្រីចូលរួមចំនួន ៣៤នាក់។

កិច្ចប្រជុំនេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

១)-ពិនិត្យមើលឡើងវិញនូវការអនុវត្តកម្មវិធីកន្លងមក ទាំងលទ្ធផលសម្រេចបាន និងបញ្ហាប្រឈមនានា

២)-រៀបចំផែនការអភិវឌ្ឍ និងវិនិយោគរបស់កម្មវិធីសាលារៀនជំនាន់ថ្មីឆ្នាំ២០២១

៣)-រៀបចំផែនការពង្រឹងសមត្ថភាពបច្ចេកទេសដល់បុគ្គ លិកនិងមន្ត្រីតាមសាលារៀនអំពីគោលការណ៍ណែនាំប្រតិបត្តិរបស់កម្មវិធីសាលារៀនជំនាន់ថ្មីតាមរយៈការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

៤)-ការពង្រឹងនិរន្តរភាពស្វ័យប្រតិបត្តិការរបស់សាលារៀននីមួយៗ និងការត្រៀមខ្លួនសម្រាប់ការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មី។

កិច្ចប្រជុំប្រចាំឆ្នាំរបស់កម្មវិធីសាលារៀនជំនាន់ថ្មី ជាឱកាសសម្រាប់បុគ្គលិកបានជួបជុំគ្នាធ្វើបទបង្ហាញអំពីគោលនយោបាយ គោលការណ៍ បញ្ហាប្រឈម ការដោះស្រាយ និងលទ្ធផលតាមផ្នែកនីមួយៗ។ លទ្ធផលសម្រេចរបស់អង្គវិបស្សនា រួមមាន៖

១)-កាត់បន្ថយការចំណាយលើក្រដាសដោយជំនួសមកវិញនូវការប្រើប្រាស់ជាឯកសារទន់(Soft Copy)។

២)-ត្រូវបញ្ចប់ផែនការរបស់សាលារៀននីមួយៗមុនពេលថវិកាក្រសួងអប់រំ យុវជន និងកីឡាមកដល់ត្រឹមសប្តាហ៍ទី១ក្នុងខែមីនា។

៣)-ការខ្វះខាតកុំព្យូទ័រនៅតាមសាលា ការជួសជុល និងការទិញកុំព្យូទ័រដែលមានគុណភាពល្អជាងមុននឹងត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំខាងមុខ

៤)-ការជ្រើសរើសជំនួយការអាយស៊ីធី(ICT) តាមសាលារៀន និងបុគ្គលិក ICT

៥)-ការទិញសុសវែរគ្រប់គ្រងទិន្នន័យសម្រាប់សាលារៀននីមួយៗ

៦)-ចាត់តាំងអ្នកគ្រប់គ្រងតាមដានប្រព័ន្ធទិន្នន័យ

៧)-ការពង្រឹងសមត្ថភាពការទទួលខុសត្រូវរបស់បុគ្គលិកដើម្បីត្រៀមពង្រីកសាលារៀនជំនាន់ថ្មីនៅពេលអនាគត

៨)-ការពិនិត្យតាមដានលទ្ធផលរំពឹងទុកក្នុងកម្មវិធីសកម្មភាព កម្មវិធីសាលារៀនជំនាន់ថ្មី

៩)-កែសម្រួលឧបករណ៍វាយតម្លៃសាលារៀនជំនាន់ថ្មី ដែលទាក់ទងការវាយតម្លៃសាលារៀនដើម្បីផ្តល់វិញ្ញាបនបត្រ

១០)-កំណត់កាលបរិច្ឆេទប្រជុំឆ្លងឧបករណ៍សម្រេចតាមអ្នកទទួលខុសត្រូវ។

ការរៀបចំអង្គវិបស្សនាប្រចាំឆ្នាំពិតជាបានផ្តល់នូវពេលវេលាល្អមួយសម្រាប់គ្គលិក កម្មវិធីធ្វើការឆ្លុះបញ្ចាំងការងារនាពេលកន្លងមក និងលើកទិសដៅអនុវត្តការងារបន្ត៕



*សកម្មភាពធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់គ្នានៅក្នុងការប្រជុំអង្គវិបស្សនាប្រចាំឆ្នាំនៅក្នុងខេត្តស្ទឹងត្រែង។*




# សិក្ខាសាលាស្តីពី "វិទ្យាសាស្ត្រ" របស់កម្មវិធីសាលារៀនជំនាន់ថ្មី

នៅថ្ងៃទី១-២ ខែមីនា ឆ្នាំ២០២១ កម្មវិធីសាលារៀនជំនាន់ថ្មីបានរៀបចំសិក្ខាសាលាស្តីពី "វិទ្យាសាស្ត្រ" នៅវិទ្យាល័យព្រែកលៀប ដែលមានអ្នកចូលរួមសរុបចំនួន ២០នាក់។ សិក្ខាសាលានេះមានគោលបំណងបង្ហាញពីៈ

១)-ការសិក្សាបែបស្ទែម (STEM)
២)-វិធីសាស្ត្របង្រៀននៅសតវត្សរ៍ទី២១
៣)-កម្មវិធីសាលារៀនជំនាន់ថ្មីឆ្លើយតបទៅនឹងការរៀនបែបសតវត្សរ៍ទី២១
៤)-ការកំណត់វត្ថុបំណង និងការធ្វើតេស្ត និង
៥)-ការអប់រំបំណិនជីវិត។

សិក្ខាកាមបានពិភាក្សាជាក្រុមដោយផ្តោតទៅលើវិធីសាស្ត្របង្រៀន និងរៀន ផ្លាស់ប្តូរបទពិសោធន៍បង្រៀន ការដោះស្រាយបញ្ហាប្រឈម ការបង្កើតធនាគារសំនួរសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ វិធីវិទ្យាសាស្ត្រ សុសវែរវិទ្យាសាស្ត្រ ការពិសោធន៍តាមមេរៀន ការសរសេរសន្លឹករបាយការណ៍ពិសោធន៍ និងការប្រើប្រាស់ការពិសោធន៍តាមអេឡិចត្រូនិក (E-Lab)។

ជាលទ្ធផល លោកគ្រូអ្នកគ្រូបានសិក្សាអំពីចំណេះដឹង និងមេរៀនពិសោធន៍ល្អថ្មីៗពីសិក្ខាសាលា ហើយរៀបចំផែនការអនុវត្តក្នុងថ្នាក់រៀនដើម្បីឱ្យការរៀន និងបង្រៀនមានលក្ខណៈល្អប្រសើរ និងឈានដល់ការប្រើប្រាស់វិធីសាស្ត្របង្រៀននៅក្នុងសតវត្សរ៍ទី២១។

កម្មវិធីសាលារៀនជំនាន់ថ្មីបានដំណើរការដល់ឆ្នាំទី៦ ដែលមានសមត្ថភាពទាក់ទាញចំណាប់អារម្មណ៍អ្នកសិក្សា និងដៃគូអភិវឌ្ឍន៍ជាច្រើនតាមរយៈសមិទ្ធផលកម្មវិធីរបស់ខ្លួន ដែលមានការរីកសុះសាយ ទាំងផ្នែកសារព័ត៌មាន និងការបោះពុម្ពផ្សាយក្នុងវិស័យសិក្សាក្រោមជំនួយហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡា និងប្រតិបត្តិដោយអង្គការខេប នៅក្នុងខេត្តចំនួន៤ គឺៈ កំពង់ចាម រាជធានីភ្នំពេញ កណ្តាល និងកំពង់ស្ពឺ។



*សកម្មភាពលោកគ្រូអ្នកគ្រូកំពុងពិសោធន៍ការរៀបក្រដាសឱ្យមានលំនឹង។*

# ការប្រើប្រាស់ឧបករណ៍វាយតម្លៃចុងឆ្នាំសិក្សា

គម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRACIII) បានរៀបចំសិក្ខាសាលាស្តីពី "ការប្រើប្រាស់ឧបករណ៍វាយតម្លៃបញ្ចប់ឆ្នាំសិក្សា" ចំនួនពីរថ្ងៃ ចាប់ពីថ្ងៃទី១១-១២ ខែមករា ឆ្នាំ២០២១ ដែលមានអ្នកចូលរួមសរុបចំនួន ១៤នាក់ជាអ្នកស្ម័គ្រចិត្ត និងបុគ្គលិក អង្គការខេប។ សិក្ខាសាលានេះមានគោលបំណង៖ ១)-ស្វែងយល់អំពីនីតិវិធីវាយតម្លៃអំណានថ្នាក់ដំបូង និងថ្នាក់មត្តេយ្យ ២)-ពង្រឹងសមត្ថភាពសិក្ខាកាមលើការប្រើប្រាស់កម្មវិធី Tangerine ដើម្បីបង្កើនការវាយតម្លៃប្រកបដោយគុណភាព និងមានប្រសិទ្ធភាព ៣)-រំលឹកឡើងវិញអំពីការប្រើប្រាស់ឧបករណ៍វាយតម្លៃកម្មវិធីអំណាន ដូចជា៖ វាយតម្លៃគ្រូបង្វឹក ឬគ្រូថ្នាក់ទី១ ទី២ និងទី៣ មាតាបិតា សិស្សមានតម្រូវការបន្ថែម និងសិស្សធំជួយសិស្សតូច ៤)-រៀបចំផែនការចុះវាយតម្លៃតាមរយៈការធ្វើតេស្ត EGRA និងកម្មវិធីអំណានសម្រាប់គម្រោង។

អំឡុងពេលសិក្ខាសាលា អ្នកចុះប្រមូលទិន្នន័យបានអនុវត្តន៍ជាមួយក្រុមការងារជាច្រើនលើកច្រើនសារ ដើម្បីប្រាកដថាការចុះប្រមូលទិន្នន័យតាមសាលារៀនគោលដៅនីមួយៗទទួលបានប្រសិទ្ធភាពខ្ពស់។ សិក្ខាកាមបានអនុវត្តការប្រើប្រាស់កម្មវិធី Tangerine ផ្ទាល់នៅសាលារៀនជំនាន់ថ្មី សាលាបឋមសិក្សា ហ៊ុន សែន កំពង់ចាមប្រកបដោយប្រសិទ្ធភាព៕


*ការចុះអនុវត្តន៍សាកល្បងនៅសាលារៀនជំនាន់ថ្មី សាលាបឋមសិក្សា ហ៊ុន សែន កំពង់ចាម។*

# គម្រោងកុមារកម្ពុជារីករាយចុះធ្វើតេស្តវាយតម្លៃអំណានថ្នាក់ដំបូង


*ការចុះប្រមូលទិន្នន័យនៅសាលារៀនគោលដៅក្នុងខេត្តក្រចេះ។*

គម្រោងកុមារកម្ពុជារីករាយ បានចុះធ្វើតេស្តវាយតម្លៃអំណានថ្នាក់ដំបូង (EGRA) ចុងឆ្នាំសិក្សា នាថ្ងៃទី២២-២៧ ខែមករា ឆ្នាំ២០២១ នៅតាមសាលារៀនគោលដៅចំនួន ២២ ដែលមានសិស្សចូលរួមធ្វើតេស្តសរុប ៦៧៨នាក់ ជាសិស្សថ្នាក់ទី២ ទី៣ និងទី៤ ក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ និងក្រចេះ។ គោលបំណងចុះតាមដាននេះ ដើម្បីធានាថាលទ្ធផលសិក្សាសិស្សមានការផ្លាស់ប្តូរជាវិជ្ជមាន និងស្ថិតនៅក្នុងកម្រិតកំពុងរីកចម្រើនលឿន ឬកម្រិតណាផ្សេងទៀត។ ការធ្វើតេស្តនេះ គម្រោងបានសហការជាមួយមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុកធ្វើជាអ្នកចុះធ្វើតេស្តផ្ទាល់តែម្តង៕





# ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការសិក្សា ប្រជុំ និងទំនាក់ទំនងគ្រួសារ ក្នុងបរិបទជំងឺកូវីដ-១៩

ជំងឺកូវីដ-១៩ត្រូវបានរកឃើញនៅទីក្រុងវូហានក្នុងប្រទេសចិនកាលពីចុងឆ្នាំ ២០១៩ ហើយវាបានរីករាលដាលពាសពេញពិភពលោករហូតមកដល់បច្ចុប្បន្ននេះ។ ជំងឺកូវីដ-១៩បានផ្ទុះឡើងជាលើកទី៣ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២១ នៅកោះពេជ្រដែលបណ្ដាលឱ្យគ្រឹះស្ថានសិក្សាទាំងអស់ទូទាំងប្រទេសត្រូវបានបិទទ្វារម្តងទៀត ហើយត្រូវបន្តការប្រើប្រាស់ការសិក្សាបែបនិម្មិត (ការរៀនពីចម្ងាយ)ដើម្បីជំរុញសិស្សានុសិស្ស និងនិស្សិតឱ្យបន្តការសិក្សានៅតាមផ្ទះតាមរយៈឧបករណ៍មួយចំនួន ដូចជា Telegram, ZOOM, Google Meet, Microsoft Team, Skype, Messenger, WhatsApp និងកម្មវិធីជាច្រើនទៀតដែលកំពុងប្រើប្រាស់នៅតាមសាលារៀនគោលដៅអង្គការខេប។ យើងអាចសន្សំពេលវេលាបានច្រើនពីការប្រើប្រាស់ឧបករណ៍ទាំងនេះ។ ចំពោះសិស្សដែលមិនមានលទ្ធភាពទទួលបានការសិក្សាបែបនិម្មិត ពួកគេអាចទៅយកសន្លឹកកិច្ចការពីលោកគ្រូអ្នកគ្រូនៅសាលារៀនរបស់ខ្លួនយកទៅធ្វើនៅផ្ទះបាន។ ដូច្នេះ ការសិក្សាតាមអនឡាញ ឬការសិក្សាបែបនិម្មិតជាជម្រើសដ៏ល្អបំផុតដើម្បីចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ក្នុងពេលដែលប្រទេសរបស់យើងស្ថិតក្នុងស្ថានភាពលំបាកនេះ។

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាលថ្នាក់ជាតិនៃកម្មវិធីសាលារៀនជំនាន់ថ្មី

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ កម្មវិធីសាលារៀនជំនាន់ថ្មីបានរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលថ្នាក់ជាតិនៃកម្មវិធីសាលារៀនជំនាន់ថ្មី តាម រយៈប្រព័ន្ធអេឡិចត្រូនិក (ZOOM) ដែលដឹកនាំដោយឯកឧត្តម ឡោ ឆវណ្ណា ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ ដើម្បីពិនិត្យមើល ១)-របាយការណ៍កម្មវិធីសម្រាប់ឆ្នាំសិក្សា ២០១៩-២០២០ ដែលគ្របដណ្តប់លើសកម្មភាពសំខាន់ៗ សមិទ្ធផល និងបញ្ហាប្រឈម ២)-របាយការណ៍អំពីការវាយតម្លៃទទួលស្គាល់គុណភាពសម្រាប់សាលារៀនជំនាន់ថ្មីទាំង៦សម្រាប់ឆ្នាំ២០២០ ៣)-ការធ្វើសវនកម្មសាលារៀនជំនាន់ថ្មីដោយអាជ្ញាធរសវនកម្មជាតិសម្រាប់ឆ្នាំ២០១៩ ៤)-ការឆ្លងឯកសារទស្សនាទាននៃការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មី និង ៥)-ការពិភាក្សារួមគ្នាដើម្បីដោះស្រាយបញ្ហាប្រឈម ការផ្តល់អនុសាសន៍ពីក្រុមប្រឹក្សាភិបាលដើម្បីកែលម្អការអនុវត្តកម្មវិធី និងការធ្វើផែនការបន្ត។ កិច្ចប្រជុំនេះបានផ្តល់នូវសារៈសំខាន់ដល់ការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីល្អប្រសើរ។



សកម្មភាពពិភាក្សាអំពីការសាងសង់សាលប្រជុំនៅតាមសាលារៀនជំនាន់ថ្មីអំឡុងកិច្ចប្រជុំតាមអនឡាញ




# សេចក្តីណែនាំក្រសួងអប់រំឱ្យអនុវត្តកម្មវិធីត្រីវិស័យនៅមធ្យមសិក្សា

កម្មវិធី "ត្រីវិស័យ" (Trey Visay) ជាកម្មវិធីប្រឹក្សាតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់ឱ្យសិស្សស្វ័យវាយតម្លៃអំពីបុគ្គលិកលក្ខណៈ មុខរបរ ទីផ្សារការងារ ដោយផ្អែកលើមុខវិជ្ជាដែលខ្លួនពូកែ។ សិស្សានុសិស្សអាចមើលព័ត៌មានទាក់ទងនឹងមុខជំនាញ ទីតាំងសាលារៀន និងលេខទូរសព្ទទំនាក់ទំនងរបស់សាលារៀននីមួយៗបានយ៉ាងងាយស្រួល។

កម្មវិធីត្រីវិស័យត្រូវបានក្រសួងអប់រំ យុវជន និងកីឡា ចេញសេចក្តីណែនាំជាផ្លូវការនៅថ្ងៃចន្ទ៤កើតខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២១ ឱ្យអនុវត្តនៅតាមគ្រឹះស្ថានមធ្យមសិក្សារាជធានី-ខេត្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។ កម្មវិធីនេះត្រូវបានបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចសហការជាមួយអង្គការ ខេប។

កម្មវិធីត្រីវិស័យបានផ្តល់ព័ត៌មានអំពីអាជីពការងារ យើងអាចប្រើប្រាស់ដោយមិនមានអ៊ីនធឺណែត (Offline)បាន។ វាគឺជាកម្មវិធីដ៏មានសារៈសំខាន់សម្រាប់ផ្តល់ចំណេះដឹង និងព័ត៌មានចាំបាច់ ដើម្បីកំណត់គោលដៅ ព្រមទាំងចេះបង្កើតផែនការសម្រាប់ ថ្ងៃអនាគត។ សិស្សម្នាក់ៗអាចបង្កើតគណនីផ្ទាល់ខ្លួនដើម្បីចូលទៅក្នុងកម្មវិធី អាចកំណត់ភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន ស្វែងរក ឱកាសការងារជាច្រើននៅប្រទេសកម្ពុជា និងមើលវីដេអូអំពីមុខរបរការងារផ្សេងៗ។

កម្មវិធីនេះជួយសិស្សក្នុងការកំណត់នូវអត្តសញ្ញាណ និងការជ្រើសរើសយកអាជីពដែលមានសក្តានុពលសម្រាប់អនាគតរបស់ពួកគាត់៕


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៥ អយក.សណន

**សេចក្តីណែនាំ**
**ស្តីពី**
**ការអនុវត្តកម្មវិធីត្រីវិស័យនៅតាមគ្រឹះស្ថានមធ្យមសិក្សា**

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) បានបង្កើតកម្មវិធីផ្តល់ប្រឹក្សាតាមប្រព័ន្ធអេឡិចត្រូនិច "ត្រីវិស័យ" (TreyVisay) ក្នុងគោលបំណងឱ្យសិស្សស្វ័យវាយតម្លៃអំពីបុគ្គលិកលក្ខណៈ មុខរបរ និងឈ្វេងយល់អំពីព័ត៌មានគ្រឹះស្ថានសិក្សានិងទីផ្សារការងារ។

ដើម្បីឱ្យសិស្សអនុវត្តកម្មវិធីត្រីវិស័យ នៅតាមគ្រឹះស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងគ្រឹះស្ថានសិក្សាទាំងអស់ដូចខាងក្រោម៖

**១. ភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត**
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រឹះស្ថានសិក្សាក្រោមឱវាទ ដើម្បីឱ្យសិស្សានុសិស្សចូលប្រើប្រាស់កម្មវិធីត្រីវិស័យប្រកបដោយប្រសិទ្ធភាព
- ណែនាំគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទ រៀបចំផែនការអនុវត្តកម្មវិធីត្រីវិស័យ ឱ្យបានគ្រប់កម្រិតថ្នាក់
- ចូលរួមដោះស្រាយបញ្ហាប្រឈមផ្សេងៗ ជាមួយគ្រឹះស្ថានសិក្សា ក្នុងការប្រើប្រាស់កម្មវិធីត្រីវិស័យដោយស្មារតីទទួលខុសត្រូវខ្ពស់
- កៀរគរធនធាន និងដៃគូសហការ ដើម្បីគាំទ្រដំណើរការអនុវត្តកម្មវិធីត្រីវិស័យឱ្យមានប្រសិទ្ធភាព
- ពិនិត្យតាមដាន និងផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ អំពីការអនុវត្តកម្មវិធីត្រីវិស័យ នៅតាមគ្រឹះស្ថានសិក្សា ជូននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។

**២. ភារកិច្ចរបស់គ្រឹះស្ថានសិក្សា**
- រៀបចំផែនការណែនាំការអនុវត្តកម្មវិធីត្រីវិស័យដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់
- ចាត់តាំងឱ្យមានអ្នកទទួលខុសត្រូវក្នុងការណែនាំ និងប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្ស
- ចូលរួមដោះបញ្ហាប្រឈមផ្សេងៗ ក្នុងការប្រើប្រាស់កម្មវិធីត្រីវិស័យ ដោយស្មារតីទទួលខុសត្រូវខ្ពស់
- កៀរគរធនធានដៃគូសហការ ដើម្បីគាំទ្រដំណើរការអនុវត្តកម្មវិធីត្រីវិស័យឱ្យមានប្រសិទ្ធភាព
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ អំពីការអនុវត្តកម្មវិធីត្រីវិស័យ ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ : (៨៥៥-២៣) ២១០ ៧០៥ / ២១០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh


**៣. តួនាទីរបស់គ្រូទទួលបន្ទុកអនុវត្តកម្មវិធីត្រីវិស័យ**
- រៀបចំផែនការប្រចាំឆ្នាំ ស្តីពីការផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្សគ្រប់កម្រិតថ្នាក់
- អនុវត្តការផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់កម្មវិធីត្រីវិស័យ
- សម្របសម្រួលក្នុងដំណើរការប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្ស
- ណែនាំសិស្ស អំពីរបៀបដំឡើងកម្មវិធីត្រីវិស័យក្នុងទូរសព្ទឆ្លាតវៃ ឬកុំព្យូទ័របន្ទះ (Tablet) ពីក្នុង App Store ឬ Play Store
- ណែនាំរបៀបប្រើប្រាស់លម្អិតកម្មវិធីត្រីវិស័យ ដូចក្នុងឧបសម្ព័ន្ធជូនភ្ជាប់
- រៀបចំរបាយការណ៍ អំពីលទ្ធផលនៃការប្រើប្រាស់កម្មវិធីត្រីវិស័យរបស់សិស្ស ជូនគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា។

ក្រសួងសង្ឃឹមថា លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត គណៈគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សា និងលោកគ្រូ អ្នកគ្រូទទួលបន្ទុកអនុវត្តកម្មវិធីត្រីវិស័យនៅតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈទាំងអស់ ចូលរួមអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ៤ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- អគ្គនាយកដ្ឋានអប់រំ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី «ដើម្បីជូនជ្រាបជាព័ត៌មាន»
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត «ដើម្បីមុខការ»
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ





# អត្ថប្រយោជន៍ការវគ្គបំប៉នសមត្ថភាពបង្រៀនដល់គ្រូកិច្ចសន្យា

គម្រោងកុមារកម្ពុជារីករាយ (HCC) ក្រោមជំនួយហិរញ្ញប្បទានពីមូលនិធិគីនធាន់ស្ទីហ្វទុង បានរៀបចំវគ្គបំប៉នសមត្ថភាពគ្រូកិច្ចសន្យាស្តីពី "វិធីសាស្ត្របង្រៀន" ដល់សាលារៀនគោលដៅរបស់ខ្លួនក្នុងខេត្តសៀមរាប ត្បូងឃ្មុំ និងរតនគិរី ចាប់ពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០២១ មានរយៈពេលប្រាំៗថ្ងៃក្នុងខេត្តនីមួយៗ ដោយមានសិក្ខាកាមចូលរួមសរុបទាំងអស់ ៨៧នាក់ មកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុក គ្រូជាប់កិច្ចសន្យា និងអ្នកពាក់ព័ន្ធដទៃទៀត។ ការរៀបចំវគ្គនេះឡើងដើម្បីកសាងសមត្ថភាពគ្រូកិច្ចសន្យាឱ្យក្លាយទៅជាគ្រូបង្រៀននៅសាលារដ្ឋប្រកបដោយភាពទទួលខុសត្រូវ និងមានគុណភាពខ្ពស់។

សិក្ខាកាមបានសិក្សាអំពីចំណេះដឹងទាក់ទងនឹងវិធីសាស្ត្របង្រៀនមួយចំនួន ដូចជា ១)-ចិត្តវិទ្យាកុមារក្នុងការបង្រៀន និងរៀន ២)-យល់ដឹងពីតួនាទី និងភារកិច្ចរបស់គ្រូបង្រៀននៅកម្មវិធីសិក្សារដ្ឋ ៣)-យកទ្រឹស្តីទៅអនុវត្តក្នុងថ្នាក់រៀនជាក់ស្តែង ៤)-បង្កើនវិធីសាស្ត្របង្រៀន និងរៀន ដើម្បីឆ្លើយតបនឹងប្រសិទ្ធភាព និងគុណភាព ៥)-ចែករំលែកបទពិសោធន៍ ក៏ដូចជាវិធីសាស្ត្រល្អៗឱ្យគ្នាទៅវិញទៅមក ៦)-ប្រើប្រាស់សៀវភៅសិស្ស និងសៀវភៅគ្រូរបស់ក្រសួងក្នុងការធ្វើកិច្ចតែងការបង្រៀន និងធ្វើការវាយតម្លៃការសិក្សារបស់សិស្សនៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ៧)-យល់ដឹងពីទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។

លោក **គាំ វ៉ាន់ឌី** ប្រធានការិយាល័យបឋមនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរីបានមានប្រសាសន៍ថា "**ការបណ្តុះបណ្តាលនេះមានអត្ថប្រយោជន៍ខ្លាំងណាស់ ព្រោះបានជួយដល់ការងារបង្រៀន និងរៀនដល់លោកគ្រូអ្នកគ្រូ។ ម្យ៉ាងវិញទៀត សាលារៀនគោលដៅរបស់គម្រោងកុមារកម្ពុជារីករាយពិតជាស្អាត មានក្រាលការ៉ូ ក្តារខៀនស្អាត ងាយស្រួលដល់ការបង្រៀន និងរៀនដល់សិស្ស។**"

វគ្គបំប៉នសមត្ថភាពដល់គ្រូកិច្ចសន្យានេះពិតជាមានអត្ថប្រយោជន៍ខ្លាំងណាស់សម្រាប់ពង្រឹងសមត្ថភាពបង្រៀនឱ្យមានភាពល្អប្រសើរជាងមុន។ លោកគ្រូអ្នកគ្រូបានសំណូមពរដល់អង្គការ ខេប ឱ្យបន្តសកម្មភាពបណ្តុះបណ្តាលសមត្ថភាពគ្រូជួយដល់ខេត្តរតនគិរី ដើម្បីធ្វើឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ក្នុងឆ្លើយតបទៅនឹងតម្រូវរបស់គ្រូ និងសាលារៀននៅមូលដ្ឋានជាក់ស្តែងក្នុងបំណងលើកកម្ពស់ការអប់រំកុមារឱ្យមានការរីកចម្រើន៕



*សកម្មភាពពិភាក្សាក្រុមដ៏រលូន និងប្រកបដោយកិច្ចសហការរបស់លោកគ្រូអ្នកគ្រូនៅសាលាបឋមសិក្សាទឹកជ្រៅ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។*





# ខ្មែរបរិបទនីយកម្មមេរៀនបំណិនជីវិតចំនួន៨ក្បាល



*សកម្មភាពលោកគ្រូអ្នកគ្រូកំពុងពិនិត្យលើពាក្យ ឃ្លា ប្រយោគ និងខ្លឹមសារម៉ូឌុលនីមួយៗក្នុងអំឡុងសិក្ខាសាលាពិគ្រោះយោបល់លើកទី២នៅក្រុងកំពង់ចាម។*

គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២ស្តីពី “ខ្មែរបរិបទនីយកម្មមេរៀនបំណិនជីវិតចំនួន០៨ក្បាល” ដែលមានរយៈពេលចំនួនបីថ្ងៃ គឺនៅថ្ងៃទី២៥-២៧ ខែមករា ឆ្នាំ២០២១ នៅសាលប្រជុំសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដោយមានសិក្ខាកាមចូលរួមសរុប ៤៨ នាក់ មកពីសាលាគោលដៅចំនួន១៤ ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ ព្រមទាំងសមាជិកក្រុមការងារគម្រោងមកពីនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា និងលោកគ្រូអ្នកគ្រូ។

សិក្ខាសាលានេះមានវត្ថុបំណង ដើម្បីៈ ១)-ប្រមូលសមាសភាពចូលពីភាគីពាក់ព័ន្ធនូវចំណុចដែលត្រូវកែសម្រួលបន្ថែមនៅក្នុងម៉ូឌុលបច្ចុប្បន្ន ២)-សិក្សាពីការយល់ឃើញ និងសំណូមពរទាក់ទងនឹងខ្មែរបរិបទនីយកម្មម៉ូឌុលបច្ចុប្បន្ន។ ក្នុងសិក្ខាសាលានេះ លោកគ្រូអ្នកគ្រូត្រូវបានបែងចែកជាក្រុមពិភាក្សាតូចៗ ដើម្បីពិនិត្យអក្ខរាវិរុទ្ធ ពាក្យ ឃ្លា និងប្រយោគ ដែលត្រូវកែសម្រួលនៅក្នុងកម្មវិធីភេសប្រនហ្ស៍ (P.A.C.E Bronze) ដែលមានកម្មវិធីសិក្សាសម្រាប់សិស្សចំនួនពីរក្រុម គឺកម្មវិធីសិក្សាសម្រាប់ក្មេងស្រីជំទង់(អាយុ១១-១៣ឆ្នាំ) និងកម្មវិធីសិក្សាសម្រាប់ក្មេងស្រីពេញវ័យ(អាយុ ១៤-១៧ឆ្នាំ)។ ក្រុមនីមួយៗបានបង្ហាញពីលទ្ធផលក្នុងម៉ូឌុលនីមួយៗ បញ្ហាប្រឈមក្នុងពេលបង្រៀនសិស្ស និងចែករំលែកបទពិសោធន៍ទៅវិញទៅមកក្នុងការបង្រៀនតាមមេរៀននីមួយៗ។

គម្រោង LSLAG គឺជាគម្រោងមួយកសាងការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពរបស់កុមារីឱ្យមានទំនុកចិត្ត សមត្ថភាពធ្វើការសម្រេចចិត្ត និងចេះធ្វើផែនការសម្រាប់អនាគតនៅពេលពួកគាត់ក្លាយទៅជាមនុស្សពេញវ័យ។

**គម្រោង LSLAG:**
**“ការផ្តល់នូវសមត្ថភាពសម្រាប់ក្មេងស្រីគឺដើម្បីរស់នៅប្រកបដោយប្រសិទ្ធភាពនៅក្នុងសង្គម ”។**

ម៉ូឌុលនីមួយៗត្រូវបានត្រួតពិនិត្យដោយយកចិត្តទុកដាក់ មុននឹងធ្វើការបញ្ជូនទៅកាន់អ្នកពាក់ព័ន្ធផ្សេងទៀត៕




# ប្រសិនបើអ្នកចង់ឱ្យគេជួយ លុះត្រាអ្នកត្រូវខិតខំប្រឹងប្រែងតស៊ូគ្រប់បែបយ៉ាងជួយខ្លួនឯងឱ្យអស់ពីលទ្ធភាពជាមុនសិន




អ្នកគ្រូ ហៃ ណារីន គឺជាអតីតគរុនិស្សិតអាហារូបករណ៍គម្រោងអប់រំកុមារីរបស់អង្គការ ខេប នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ហើយសព្វថ្ងៃនាងជាគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ និងភាសាអង់គ្លេស នៅវិទ្យាល័យ ហ៊ុន សែន ត្បែង ស្ថិតក្នុងស្រុកស្ទឹងសែន ខេត្តកំពង់ធំ។

បន្ទាប់ពីបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៦ នាងបានប្រឡងជាប់គ្រូកម្រិតមូលដ្ឋាន ដែលត្រូវទៅសិក្សាឆ្ងាយពីផ្ទះ។ នាងមកស្នាក់នៅក្នុងទីក្រុងកំពង់ចាមដើម្បីបន្តការសិក្សា ប៉ុន្តែវាជាបន្ទុកបន្ថែមមួយទៀតលើការចំណាយរបស់គ្រួសារនាង ដែលមានជីវភាពខ្វះខាត និងគ្មានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ជួយឧបត្ថម្ភឱ្យនាងបានសិក្សាបន្ត។ កាលៈទេសៈបែបនោះបានធ្វើឱ្យនាងកាន់តែពិបាកចិត្តច្រើនលើការចំណាយទិញសម្ភារៈសិក្សា និងអាហារហូបចុកប្រចាំថ្ងៃ ព្រោះនាងជួបការលំបាកកាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ជាសំណាងល្អនៅដើមឆ្នាំ២០១៧ ដោយសារនាងទទួលបានអាហារូបករណ៍ពីអង្គការ ខេប តាមរយៈគម្រោងអប់រំកុមារី (GEI) ដែលបានធ្វើឱ្យស្ថានភាពជីវិតរបស់នាងមានភាពល្អប្រសើរឡើង។ អំឡុងពេលអន្តរាគមន៍ពីគម្រោង GEI នាងបានកាត់បន្ថយការចំណាយរបស់គ្រួសារ ហើយមានពេលវេលាសិក្សាបានច្រើនប្រកបដោយសេចក្តីសប្បាយរីករាយ។

លោកគ្រូអ្នកគ្រូបានលើកទឹកចិត្ត ផ្តល់ការអប់រំទូន្មានប្រដៅ ផ្តល់បទពិសោធន៍ជីវិត និងចំណេះដឹងល្អៗឱ្យនាងខិតខំតស៊ូសិក្សា រហូតដល់បានបញ្ចប់ការសិក្សាវិជ្ជាជីវៈគ្រូបង្រៀន។ គម្រោងអប់រំកុមារីបានជួយផ្លាស់ប្តូរជីវិតកុមារីដែលទន់ជ្រាយដូចជារូបនាងឱ្យមានភាពក្លាហាន ចេះម្ចាស់ការរស់នៅម្នាក់ឯង មានទំនុកចិត្ត ធ្វើអ្វីៗប្រកបដោយការគិតពិចារណាស៊ីជម្រៅ និងចេះថ្លឹងថ្លែងរកហេតុ និងរកផលមុននឹងសម្រេចចិត្តធ្វើសុភវិនិច្ឆ័យចំពោះអ្វីដែលកើតឡើងក្នុងជីវិតនាង។ នាងបានយកមេរៀនពិសោធន៍ល្អៗទាំងនោះមកអនុវត្តន៍ក្នុងជីវិតជាក់ស្តែងប្រចាំថ្ងៃប្រកបដោយភាពរីកចម្រើនប្រសើរជាងមុន៕





# តួនាទីស្ត្រីក្នុងវិស័យឯកជន

កញ្ញា ស៊ី សុខឡេង អាយុ២៣ឆ្នាំ រស់នៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ជាអតីតនិស្សិតអាហារូបករណ៍គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា សិក្សាថ្នាក់បរិញ្ញាបត្រពាណិជ្ជកម្ម ឯកទេសគណនេយ្យ ក្នុងឆ្នាំសិក្សា ២០១៦-២០២០ នៅសាខាសាកលវិទ្យាល័យវេស្ទើន ខេត្តកំពង់ចាម។ នាងមានបងប្អូនចំនួន ៥នាក់ រស់នៅជាមួយឪពុកម្តាយជាកសិករ។

ដោយសារគ្រួសារខ្វះខាតថវិកាសម្រាប់ផ្គត់ផ្គង់ការសិក្សា នាងបានចេញទៅស៊ីឈ្នួលគេនៅពេលទំនេរពីការសិក្សា។ នាងតែងតែស្រមៃថា ប្រសិនបើនាងប្រឡងបាក់ឌុបជាប់ នាងនឹងស្វះស្វែងរកអាហារូបករណ៍ផ្សេងៗឱ្យអស់ពីលទ្ធភាព។ នាងបានធ្វើការបណ្តើររៀនបណ្តើរ ដើម្បីជួយកាត់បន្ថយការចំណាយរបស់គ្រួសារ ហើយនាងសង្ឃឹមថានឹងមានការងារល្អមួយសម្រាប់ជួយខ្លួនឯង គ្រួសារ និងសង្គមនាពេលអនាគត។

នៅក្នុងឆ្នាំ២០១៦ ជាឱកាសល្អ នាងក៏ជោគជ័យដោយទទួលបានអាហារូបករណ៍ ១០០% ពីអង្គការ ខេប ដើម្បីបន្តការសិក្សារយៈពេល ៤ឆ្នាំនៅសាកលវិទ្យាល័យ។ ក្នុងនាមជានិស្សិតក្រោមការគ្រប់គ្រងរបស់គម្រោង នាងមានការផ្លាស់ប្តូរជាច្រើន ដូចជាមានភាពក្លាហាន ចំណេះដឹងភាសាអង់គ្លេសមានការអភិវឌ្ឍ ចេះប្រើប្រាស់កុំព្យូទ័រល្អប្រសើរ ចេះបង្កើត ក្លឹបសិក្សា ធ្វើការងារក្រុម វិភាគការសែត ការចែករំលែកបទពិសោធន៍ និងបានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាច្រើន ជាពិសេសនាងបានចូលរួមការងារស្ម័គ្រចិត្តជាមួយអង្គការផ្សេងៗ ដើម្បីជួយសង្គមឱ្យមានផលជះវិជ្ជមានត្រឡប់ទៅក្នុងសហគមន៍។ នាងមានការរីកចម្រើនច្រើន និងបានខិតខំប្រឹងប្រែងរហូតដល់ទទួលបានជោគជ័យក្នុងការសិក្សា ហើយមានលទ្ធផលល្អ។ នាងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មូលនិធិ Merali អង្គការមូលនិធិអាស៊ី ដែលបានជួយឧបត្ថម្ភគាំទ្រនាងតាមរយៈអង្គការ ខេប។

នៅក្នុងបច្ចុប្បន្ននេះ នាងធ្វើការងារនៅស្ថាប័នមីក្រូហិរញ្ញវត្ថុ អេអឹមខេ (AMK) មានទីតាំងស្ថិតនៅក្នុងក្រុងកំពង់ចាម ដោយកាន់តួនាទីជាមន្ត្រីទំនាក់ទំនងអតិថិជន៕






# "នាងខ្ញុំជាស្ត្រីមូស្លីមមានឱកាសបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា"




កញ្ញា ស្លេះ សាល់ម៉ា អាយុ ២៣ឆ្នាំ រស់នៅក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ជាអតីតនិស្សិតអាហារូបករណ៍ក្នុងគម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា(CTSP) ដែលបានបញ្ចប់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈនៅសាខាសាកលវិទ្យាល័យវេស្ទើន ខេត្តកំពង់ចាម។

មុនពេលនាងទទួលបានអាហារូបករណ៍ពីអង្គការ ខេប នាងមិនដែលដឹងអ្វីជាការងារសង្គម ឬការងារស្ម័គ្រចិត្តនោះទេ មិនដែលបានចូលរួមសិក្ខាសាលា ហើយមិនដឹងថាខ្លួនចង់រៀនអ្វីដែរ ព្រោះមិនដែលមានអ្នកជួយប្រឹក្សាយោបល់ពីការរៀនសូត្រ។ ម្យ៉ាងវិញទៀត នាងជាមនុស្សស្រីស្ងៀមស្ងាត់មិនហ៊ាននិយាយឬសួរគេ បន្ទាប់ពីប្រឡងជាប់បាក់ឌុបរួចក៏មិនដឹងថាត្រូវទៅណាទៀតព្រោះគ្រួសារក្រីក្រមិនមានលទ្ធភាពឱ្យនាងរៀនបន្ត។

បន្ទាប់ពីបានទទួលអាហារូបករណ៍ពីអង្គការ ខេប នាងមានការផ្លាស់ប្តូរជាច្រើន ដូចជា មានភាពក្លាហានជាងមុន ហ៊ាននិយាយ ហ៊ានសួរពេលជួបជាមួយមនុស្សថ្មីៗ ចូលចិត្តចូលរួមសិក្ខាសាលា និងធ្វើការងារស្ម័គ្រចិត្តជួយសង្គម។ នាងក៏បានយល់ដឹងពីជំនាញទន់ផ្សេងៗជាច្រើន ជាពិសេសបានអភិវឌ្ឍន៍ចំណេះដឹងភាសាអង់គ្លេស និងចេះប្រើប្រាស់កុំព្យូទ័របានយ៉ាងល្អ ដែលអាចអនុវត្តនៅកន្លែងធ្វើការងារបាន។ បច្ចុប្បន្ននេះ នាងជាបុគ្គលិកផ្នែករដ្ឋបាលនៅសាលារៀនឯកជនមួយក្នុងខេត្តត្បូងឃ្មុំ៕

# "ស្ត្រីជនបទជោគជ័យលើការសិក្សានៅកម្រិតថ្នាក់ឧត្តមសិក្សា"

កញ្ញា វុទ្ធី សុខគីម មានអាយុ ២៣ឆ្នាំ រស់នៅក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ជាអតីតនិស្សិតអាហារូបករណ៍គម្រោងអាហារូបករណ៍និស្សិតកម្រិតឧត្តមសិក្សា (CTSP) សិក្សាថ្នាក់បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុក្នុងឆ្នាំសិក្សា២០១៦-២០២០។ នាងមានប្អូនស្រីពីរនាក់ ប្អូនស្រីពៅរស់នៅជាមួយយាយ និងម្តាយធ្វើការនៅទីក្រុងភ្នំពេញ។

សុខគីមជាក្មេងកំព្រាឪពុកតាំងពីរៀននៅបឋមសិក្សា។ នាងតែងតែឆ្លៀតពេលទំនេរពីការសិក្សាទៅស៊ីឈ្នួលគេដើម្បីជួយសម្រួលបន្ទុកគ្រួសារ មុនពេលនាងទទួលបានអាហារូបករណ៍ពីអង្គការ ខេប។

បន្ទាប់ពីទទួលបានការគាំទ្រពីគម្រោង នាងទទួលបានចំណេះដឹងច្រើន ដូចជា ការស្គាល់ពីជីវិតរស់នៅជាក្រុម មានឱកាសបានចូលរួមវគ្គសិក្សាខ្លីៗជាច្រើន មានការអភិវឌ្ឍសមត្ថភាពក្នុងការស្វែងរកការងារ។

នៅពេលបច្ចុប្បន្ននេះ កញ្ញា សុខគីម ទទួលបានការងារធ្វើនៅក្រុមហ៊ុនអិលខេគ្រុប មានទីតាំងស្ថិតក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាន់តួនាទីជាគណនេយ្យករ៕







# ទិវាជាតិអំណាន ១១ មីនា ២០២១

អបអរសាទរទិវាជាតិអំណាន ១១ មីនា លើកទី៦ ក្រោមប្រធានបទ "**អំណានក្នុងបរិបទជំងឺកូវីដ-១៩**" ជាកម្មវិធីប្រចាំឆ្នាំ ដើម្បីលើកកម្ពស់វប្បធម៌អាន និងបង្កើនទម្លាប់អាននៅកម្ពុជា ព្រមទាំងរំលេចឱ្យឃើញអំពីទស្សនាទានថ្មីនៃអំណាន រួមទាំងខ្លឹមសារសម្រាប់អំណាន មធ្យោបាយអាន និងការផ្ដល់នូវអន្តរាគមន៍ចាំបាច់សម្រាប់គាំទ្រដល់អំណានក្នុងបរិបទជំងឺកូវីដ-១៩។

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRACIII) បានគ្រោងរៀបចំទិវាជាតិអំណាននៅតាមសាលារៀនគោលដៅក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ប៉ុន្តែត្រូវបានពន្យារពេលដោយសារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ស្របតាមសេចក្ដីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យផ្អាកការជួបជុំគ្នាមួយរយៈពេល។ គម្រោងនៅតែជំរុញលោកគ្រូអ្នកគ្រូ និងនាយកសាលាបន្តរៀបចំទិវានេះនៅសាលារៀនរៀងៗខ្លួនបន្ទាប់ពីជំងឺកូវីដ-១៩ធ្លាក់ចុះវិញ។ ជារៀងរាល់ឆ្នាំ នៅតាមសាលារៀនគោលដៅគម្រោងមានវិញ្ញាសារសម្រាប់កុមារធ្វើការប្រកួត ដូចជា ការប្រកបពាក្យ ពន្យល់ពាក្យ អានរឿងពាក្យផ្ទុយ និងអានសៀវភៅឆ្លាតកម្រិត៣។ វិញ្ញាសារអាចមានលក្ខណៈខុសប្លែកគ្នាអាស្រ័យទៅលើសាលារៀនមួយៗ។

ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីចូលរួមអបអរសាទរទិវាជាតិអំណាន ១១ មីនា ក្រសួងអប់រំ យុវជន និងកីឡា នៅតែបន្តរៀបចំការប្រារព្ធទិវាជាតិអំណានតាមប្រព័ន្ធអនឡាញ ក្នុងគោលបំណងរំឭកដល់វីរភាពរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលបានខិតខំតស៊ូពុះពារការពារមរតកវប្បធម៌ អក្សរសាស្ត្រខ្មែរ និងក្នុងគោលបំណងបណ្ដុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ ដែលសំដៅដល់ការចូលរួមចំណែកការពារ និងពង្រឹងវប្បធម៌ និងអរិយធម៌ខ្មែរ។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "*សមត្ថភាពនៃការអានមិនត្រឹមតែសមត្ថភាព និងវិធីសាស្ត្រក្នុងការបង្រៀន សម្ភារៈឧបទេសប៉ុណ្ណោះទេ អាស្រ័យទៅលើការគ្រប់គ្រងសាលារៀនដោយនាយក ការចូលរួមពីសហគមន៍ មាតាបិតា និងការរៀបចំវាយតម្លៃការសិក្សារបស់សិស្ស*"។

ប្រទេសមួយអភិវឌ្ឍន៍ទៅបានអាស្រ័យលើប្រជាជនរបស់ប្រទេសនោះសម្បូរធនធានមនុស្ស ដោយផ្ដើមចេញពីការអានសៀវភៅ៕





*សកម្មភាពកុមារអានសៀវភៅនៅក្នុងថ្នាក់រៀននៅថ្ងៃទិវាអំណានជាតិនៅសាលាបឋមសិក្សា ស្ទឹងជ័យ ដែលជាសាលាគោលដៅរបស់គម្រោងត្រាក់៣។*





# បច្ចេកទេសបង្រៀនមត្តេយ្យជំនាន់ថ្មី



សកម្មភាពអ្នកគ្រូកំពុងផាត់ពណ៌លើផ្ទាំងរូបភាព ដែលជាឯកសារសម្រាប់បង្ហាញទៅកាន់សិស្សានុសិស្សរបស់ពួកគាត់។

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRACIII) ក្រោមការឧបត្ថម្ភហិរញ្ញប្បទានពីមូលនិធិ ហ្វីនីក្ស៍ និងប្រតិបត្តិដោយអង្គការ ខេប បានរៀបចំសិក្ខាសាលាស្តីពី "**បច្ចេកទេសបង្រៀនមត្តេយ្យជំនាន់ថ្មី**" នាថ្ងៃទី២០-២២ ខែកុម្ភៈ ឆ្នាំ២០២១ នៅសាលប្រជុំក្រុមហ៊ុនធនធានអប់រំ(TTO) ក្នុងក្រុងកំពង់ចាម។ សិក្ខាសាលានេះមានសិក្ខាកាមចូលរួមចំនួន ១៤នាក់ ជាគ្រូគោលដៅមកពីខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សិក្ខាសាលានេះមានគោលបំណងៈ 1)-ស្វែងយល់អំពីគោលការណ៍មត្តេយ្យជំនាន់ថ្មី ការអភិវឌ្ឍរបស់កុមារ ការរចនាក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន 2)-ពង្រឹងសមត្ថភាពសិក្ខាកាមលើការប្រើប្រាស់វិធីសាស្ត្រថ្មី និងបច្ចេកវិទ្យាថ្មីរបស់សាលាមត្តេយ្យជំនាន់ថ្មី 3)-ណែនាំអំពីយុទ្ធសាស្ត្របង្រៀន និងរៀនរបស់សាលាមត្តេយ្យជំនាន់ថ្មី និងការអភិវឌ្ឍជំនាញទន់ដល់គ្រូមត្តេយ្យ 4)-ធ្វើការតាមដាន និងវាយតម្លៃ។ សិក្ខាសាលារយៈពេលបីថ្ងៃនេះបានប្រព្រឹត្តទៅដោយជោគជ័យ និងសម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖ ១)-នាយកសាលាទាំង៦ និងគ្រូមត្តេយ្យបានយល់ដឹងពីគោលនយោបាយសាលាមត្តេយ្យជំនាន់ថ្មី ២)-គ្រូមត្តេយ្យបានយល់ដឹងអំពីវិធីសាស្ត្របង្រៀន និងរៀនតាមរយៈល្បែងសិក្សា របៀបរៀនខុសៗគ្នារបស់កុមា ៣)-ការអភិវឌ្ឍជំនាញទន់ យុទ្ធសាស្ត្រសិក្សាតាមបែបសហការ បច្ចេកវិទ្យាព័ត៌មានវិទ្យានិងការអប់រំ ការសិក្សាផ្អែកលើគម្រោងការសិក្សាតាមរយៈការលេងល្បែងសិក្សា ការបង្កើតទម្លាប់ និងផែនការប្រចាំថ្ងៃ ជាពិសេសការវាយតម្លៃលទ្ធផលការសិក្សារបស់កុមារ៕




# ការកែលម្អមត្តេយ្យជំនាន់ថ្មី



*ការរៀបចំកែលម្អសាលាមត្តេយ្យនៅសាលាបឋមសិក្សា តាំងស្រី (ជាសាលារៀនគោលដៅគម្រោងក្នុងជុំទី៣)*

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRACIII) ក្រោមជំនួយហិរញ្ញប្បទានពីមូលនិធិហ្វីនីកស៍ និងប្រតិបត្តិដោយអង្គការ ខេប កំពុងប្រតិបត្តិការងារកែលម្អមត្តេយ្យជំនាន់ថ្មី(ជុំទី៣)ដែលមានសកម្មភាពជាច្រើន រួមមាន៖ ការរៀបចំថ្នាក់រៀន បណ្ណាល័យ សួនកុមារ និងសួនបំណិនជីវិតនៅតាមសាលារៀនគោលដៅនីមួយៗក្នុងខេត្តត្បូងឃ្មុំ និងកំពង់ចាម។ នៅក្នុងបរិបទជំងឺកូវីដ-១៩នេះ គម្រោងបានអភិវឌ្ឍន៍ផែនការសកម្មភាពកែលម្អមត្តេយ្យជំនាន់ថ្មីដើម្បីលើកកម្ពស់អំណានកុមារថ្នាក់ដំបូង។ ការពង្រឹងអំណានថ្នាក់ដំបូងរបស់កុមារជាសកម្មភាពសំខាន់ ដែលគម្រោងផ្តោតលើដោយសារមើលឃើញពីអត្រាការអានរបស់កុមាររៀននៅថ្នាក់ទី១ ទី២ និងទី៣ នៅមានកម្រិតទាប ភាគច្រើននៃកុមារអានអក្សរមិនបាន។ ដូច្នេះ គម្រោងបានព្យាយាមរកមធ្យោបាយថ្មីៗដើម្បីជួយកុមារងាយរងគ្រោះលើកកម្ពស់ផ្នែកអំណានរបស់កុមារ កាត់បន្ថយអត្រាសិស្សរៀនត្រួតថ្នាក់ កុមារអាចរៀនតាមប្រព័ន្ធអេឡិចត្រូនិកនៅផ្ទះតាមរយៈកម្មវិធីសុសវែរជាច្រើន ដូចជា រឿងអប់រំ សៀវភៅឆ្លាត អានខ្មែរ រួមទាំងថ្នាក់រៀនស្អាត បរិស្ថានជុំវិញប្រកបដោយផាសុកភាព កុមារពេញចិត្តសិក្សាជាមួយអ្នកគ្រូជាគំរូល្អសម្រាប់ពួកគេ៕

**កម្មវិធីមត្តេយ្យសិក្សា "បង្កើនគំនិតមួយសម្រាប់កុមារមួយនាក់ក្នុងពេលតែមួយ"។**





# ការវិនិយោគរបស់អង្គការ ខេប ផ្នែកហេដ្ឋារចនាសម្ព័ន្ធ

ការចូលរួមក្នុងការងាររចនាបថហេដ្ឋារចនាសម្ព័ន្ធ អង្គការ ខេប បានចាប់ផ្តើមធ្វើការវិនិយោគលើអគាររូបវន្ត ដោយធ្វើការផ្តោតលើរចនាបថច្នៃប្រឌិតថ្មីៗដែលលើកកម្ពស់ការសិក្សានៅក្នុងសតវត្សរ៍ទី២១ ដែលមានសោភ័ណភាពទាក់ទាញ និងមានផាសុកភាពក្នុងការសិក្សា។

បច្ចុប្បន្ននេះ អង្គការ ខេប មានគម្រោងចំនួន៦ ដែលកំពុងធ្វើការលើផ្នែកនេះ រួមមានគម្រោងកុមារកម្ពុជារីករាយ សាលារៀនជំនាន់ថ្មី (កម្រិតបឋមសិក្សា និងមធ្យមសិក្សា) គម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ និងគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២។ ការវិនិយោគទាំងនេះបានផ្លាស់ប្តូរបរិយាកាសនៅក្នុងសាលារៀនជាច្រើន ដោយមានសហការពីអង្គការ ខេប ធ្វើឱ្យកន្លែងសិក្សាកាន់តែទំនើប ជាពិសេស ការគាំទ្រដល់គរុកោសល្យថ្មីៗ ដូចជាការសិក្សាប្រើគោលគំនិត ការងារគម្រោង និងវិធីសាស្រ្តដទៃៗទៀត។ ម្យ៉ាងវិញទៀត រចនាបថថ្មីនេះមិនត្រឹមតែយកចិត្តទុកលើថ្នាក់រៀនតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្តោតលើអគារសិក្សាដទៃទៀតជាច្រើន រាប់ទាំងបណ្ណាល័យ បន្ទប់ពិសោធន៍វិទ្យាសាស្រ្ត សាលប្រជុំ បន្ទប់កុំព្យូទ័រ។ល។ ចាប់តាំងពីឆ្នាំ២០១៥មក អង្គការ ខេប មានលទ្ធភាពជួសជុល និងរចនាអគារសិក្សាចំនួន ៤៩២បន្ទប់ ទាំងកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ដូច្នេះ អង្គការ ខេប បានលើកកម្ពស់ការសិក្សារបស់សិស្សានុសិស្សជាមួយបរិស្ថានល្អ មានភាពច្នៃប្រឌិតថ្មីៗ និងមានលក្ខណៈទាក់ទាញសិស្សឱ្យមកសិក្សាកាន់តែច្រើនឡើង និងទាញចំណាប់អារម្មណ៍ឪពុកម្តាយផងដែរ៕



*គំរូសាលាបឋមសិក្សា រំពុក ដែលជាសាលាគោលដៅរបស់គម្រោងកុមារកម្ពុជារីករាយ (HCC)*



*បណ្ណាល័យសតវត្សរ៍ទី២១នៅសាលាបឋមសិក្សា បឹងត្រាវ បានរចនាបថឡើងដោយគម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់បី/TRACIII)*




# ការផ្លាស់ប្តូរវិជ្ជមានរបស់លោកនាយក និងគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាឈើខ្លឹម


ផ្លូវចូលខ្លោងទ្វារសាលាបឋមសិក្សាឈើខ្លឹមមានការរៀបចំរចនាដោយថ្នាក់ដឹកនាំសាលា និងគណៈកម្មការទ្រទ្រង់សាលា

សាលាបឋមសិក្សាឈើខ្លឹមមានទីតាំងស្ថិតនៅតំបន់ជនបទក្នុងភូមិឈើខ្លឹម ឃុំរំចេក មានចម្ងាយ ២៦គីឡូម៉ែត្រ ពីទីរួមស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយចំណាយពេលវេលាប្រមាណជា ៣០នាទី ធ្វើដំណើរតាមផ្លូវលំកាត់ចំការកៅស៊ូ។ នៅតំបន់នេះមានគ្រួសារជួបការលំបាកជាច្រើន ក្មេងៗទៅជួយធ្វើការចៀរជ័រជាមួយឪពុកម្តាយ និងចំណាកស្រុក មិនបានចូលរៀនត្រឹមត្រូវទេ។ សាលាបឋមសិក្សាឈើខ្លឹមមានសិស្សចំនួន ៥១២នាក់ (ស្រី២៣៥នាក់) គ្រូនិងបុគ្គលិកចំនួន ១១ នាក់ (ស្រី៥នាក់) និងគណៈកម្មការទ្រទ្រង់សាលាចំនួន ១៥នាក់ (ស្រី៣នាក់)។

លោក នេត សុឃាន់ ជានាយកសាលាបឋមសិក្សាឈើខ្លឹម ចាប់តាំងពីឆ្នាំ២០០៩ មកដល់បច្ចុប្បន្ន ដោយឆ្លងកាត់ឧបសគ្គលំបាកៗជាច្រើនទម្រាំធ្វើឱ្យសាលាលោកមានការផ្លាស់ប្តូរមុខមាត់ រីកចម្រើន មានការគាំទ្រពីសហគមន៍ អ្នកពាក់ព័ន្ធ និងសប្បុរសជនដទៃៗទៀតនៅក្នុងមូលដ្ឋាន ជាពិសេសការអន្តរាគមន៍របស់គម្រោងកុមារកម្ពុជារីករាយ (HCC)។ ចលនាឧបត្ថម្ភគាំទ្រសាលារៀនមានការទាក់ទាញកាន់តែខ្លាំងទៅៗផ្អែកលើកត្តាចម្បងៗ រួមមាន៖ ថ្នាក់ដឹកនាំសាលាប្រើបេះធ្វើការងាររួម មានតម្លាភាព យុត្តិធម៌ ភាពទទួលខុសត្រូវ សមត្ថភាព ឆន្ទៈ ក្លាហានពុះពារជំនះរាល់ឧបសគ្គ ភាពស្រុះស្រួលគ្នាផ្ទៃក្នុង និងការលះបង់ពេលវេលាលើកតំកើនការងារសាលារៀនធំជាងការងារផ្ទាល់ខ្លួន។ កិច្ចសហការយ៉ាងស្អិតរមួតរបស់គណៈកម្មការទ្រទ្រង់សាលារៀនក៏ជាការសម្រួលបន្ទុកការងារច្រើនរបស់សាលារៀនផងដែរ។

កាលពីមុនមិនទាន់មានគម្រោង HCC ចូលមកដល់ សាលាបឋមសិក្សាឈើខ្លឹមមានការលំបាកច្រើន ជាសាលាកម្រងឧបសម្ព័ន្ធរបស់សាលាបឋមសិក្សាសែនជ័យ ហើយលោក សុឃាន់ គឺជានាយករងដោយសារមិនទាន់មាននាយកដឹកនាំត្រឹមត្រូវ។ សាលាបឋមសិក្សាឈើខ្លឹមបានផ្តាច់ខ្លួនដោយឡែកចេញពីសាលាឧបសម្ព័ន្ធនៅឆ្នាំ២០១០ ក្រោមការអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាលមួយ។ ការដឹកនាំពេលនោះបានជួបការលំបាកៗ រួមមាន៖ ខ្វះអគារសិក្សាល្អ អគារចាស់ពីរទ្រុឌទ្រោមសម្រាប់ឱ្យកុមារសិក្សា។ ការជួសជុលអគារសិក្សាចាស់នេះត្រូវការថវិកាច្រើន សាលាគ្មានលទ្ធភាព បណ្ណាល័យនៅលាយឡំនិងទីចាត់ការសាលា។ អគារចាស់ត្រូវបានលិចទឹកភ្លៀង រំខានដល់សិស្សមិនអាចរៀនកើត។ ចំណែកឪពុកម្តាយសិស្សនៅក្នុងតំបន់នេះមានភាពក្រីក្រ មានលទ្ធភាពតិចតួចជួយជួសជុលអគារ តែលោក សុឃាន់ នៅតែព្យាយាមដឹកនាំពុះពារដឹកនាំសាលារៀនបន្ត។ គណៈកម្មការទ្រទ្រង់សាលារៀនមិនទាន់យល់ដឹងច្បាស់ពីតួនាទី និងភារកិច្ចខ្លួន និងពុំសូវចូលរួមការងារសាលា ហើយសហគមន៍តែងបន្ទោសសាលា និងមិនបានចូលរួមជួយកសាងសាលាស្រស្រាក់ស្រាំងនោះទេ។

បន្ទាប់ពីមានការចូលអន្តរាគមន៍គម្រោងកុមារកម្ពុជារីករាយនៅចុងឆ្នាំសិក្សា ២០១៨-២០១៩មក បានធ្វើឱ្យសាលាបឋមសិក្សាឈើខ្លឹមជួសជុលអគារសិក្សាឱ្យទៅជាថ្មី មានបរិស្ថានល្អស្អាត បង្កើតបានបណ្ណាល័យ និងទីចាត់ការដាច់ដោយឡែកពីគ្នាមានលក្ខណៈច្នៃប្រឌិតទំនើប រៀបចំតុអង្គុយធ្វើការងារមានប្លង់របៀបត្រឹមត្រូវ។ គម្រោងបានស្នើទៅមន្ទីរអប់រំ យុវជន និងកីឡាស្រុកមេមត់ឱ្យមានបណ្ណារក្សដាច់ដោយឡែក ហើយគម្រោងបានផ្តល់ថវិកាចំនួន ៦.០០០ដុល្លា រួមនឹងបដិភាគសហគមន៍ចំនួន ៦.០០០ដុល្លា ទៀតធ្វើការជួសជុលអគារឈើចាស់ទៅជាអគារដែកមួយខ្នង។ លោក សុឃាន់ ពិតជា


បរិវេណមុខថ្នាក់ និងសួនច្បារត្រូវបានរៀបចំរចនាឡើងមានសោភ័ណភាពស្អាត ប្លែក មានភាពទាក់ទាញសិស្សមកសិក្សា។



# រចនាបថហេដ្ឋារចនាសម្ព័ន្ធ



*បរិស្ថាន និងការរៀបចំសម្ភារៈក្នុងថ្នាក់ស្អាតល្អមានលក្ខណៈទាក់ទាញសិស្ស។*

មានសេចក្តីសប្បាយរីករាយ និងរំភើបចិត្តកេអ៊ីមកផ្ទឹមពុំបានដោយសារការគាំទ្រពីគម្រោង ជាពិសេសគម្រោងបានជួយបង្កើតអគារមត្តេយ្យសិក្សា។

លោក សុឃាន់ បានរៀនសូត្រ និងផ្លាស់ប្តូរវិជ្ជមានជាច្រើនពីគម្រោងក្នុងភាពជាអ្នកដឹកនាំសាលា រួមមាន៖ ហេដ្ឋារចនាសម្ព័ន្ធអគារសិក្សាបឋម និងមត្តេយ្យ ការផ្តល់វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំបឋមសិក្សា និងភាពជាអ្នកដឹកនាំមត្តេយ្យសិក្សា ការបណ្តុះបណ្តាលគណៈកម្មការទ្រទ្រង់សាលា។ ជាទូទៅ ការជ្រើសរើសគណៈកម្មការទ្រទ្រង់សាលារៀនត្រូវយកអ្នកដែលមានឥទ្ធិពលមកចូលរួម ប៉ុន្តែសាលាគ្មានប្រាក់ចំណូលឱ្យពួកគាត់ ទើបសាលាឈើខ្លឹមជ្រើសរើសតាមមេភូមិធ្វើប្រធានគណៈកម្មការ អនុភូមិមកធ្វើជាអនុប្រធានគណៈកម្មការ សមាជិកភូមិធ្វើជាហិរញ្ញិក និងបង្កើតឱ្យមានជាគ្រូបង្វឹកអំណានគាំទ្រដោយគម្រោងកុមារកម្ពុជារីករាយ សម្រាប់បង្រៀនសិស្សមានតម្រូវការពិសេស។

គម្រោង HCC បានបង្រៀនរបៀបបោះឆ្នោតជ្រើសរើសគណៈកម្មការ ដោយឱ្យឪពុកម្តាយសិស្សជាអ្នកបោះឆ្នោតជ្រើសរើសបុគ្គលដែលពួកគាត់ស្រឡាញ់ ហើយបានជាប់បេក្ខជនផ្សេងក្រៅពីសាលាតែងតាំង។

គម្រោង HCC ពិតជាបានធ្វើឱ្យគណៈកម្មការស្គាល់ច្បាស់នូវតួនាទី និងភារកិច្ចអនុវត្ត ភាពស្រុះស្រួលគ្នា កិច្ចសហការជាមួយសាលា និងសហគមន៍យ៉ាងស្អិតរមួតធ្វើឱ្យសាលាបឋមសិក្សាឈើខ្លឹមផ្លាស់ប្តូរលឿន។ សេចក្តីរំភើបចិត្តមួយទៀត គឺសាលារៀនមានឧបករណ៍តេស្តអំណានសម្រាប់វាស់ស្ទង់សមត្ថភាពសិស្សថ្នាក់ទី១ ទី២ និងទី៣ ល្បែងសិក្សាមានគ្រប់ប្រភេទ ឪពុកម្តាយអាចមកបណ្ណាល័យខ្ចីសៀវភៅទៅផ្ទះបង្រៀនកូនបាន។ ឪពុកម្តាយ និងសហគមន៍មានសេចក្តីសប្បាយរីករាយបំផុត ហើយបានមកខ្ចីល្បែងសិក្សាបន្តបន្ទាប់។ មេរៀនថ្មីមួយទៀត គឺគម្រោង HCC បានធ្វើឱ្យសាលាបឋមសិក្សាឈើខ្លឹមមានកិច្ចប្រជុំជាមួយឪពុកម្តាយជាប្រចាំដើម្បីស្វែងរកចំណុចខ្វះខាត ជាពិសេសបញ្ហាសិស្សរៀនខ្សោយសម្រាប់ធ្វើផែនការអភិវឌ្ឍន៍សាលាបន្ត។

លោក សុឃាន់ បានសង្កត់ធ្ងន់ថា "*ការគាំទ្រពីគម្រោងនេះពិតជាមានតម្លៃខ្លាំងណាស់សម្រាប់រូបខ្ញុំផ្ទាល់ និងការងារសាលា។ ជាទូទៅ ប្រសិនបើសាលារៀននីមួយៗមានត្រឹមតែបរិស្ថានស្អាត មានការចូលរួមពីសហគមន៍ គ្រូសុទ្ធតែមានសញ្ញាបត្របរិញ្ញាបត្រ អនុបណ្ឌិត ប៉ុន្តែគុណភាពសិស្សនៅតែមិនទាន់ឆ្លើយតបនឹងទាំងអស់នេះទេ សាលានោះគឺស្មើនឹងសូន្យ ឥតគុណភាព ប្រៀបដូចជាយើងស្លៀកពាក់ខោអាវស្អាតបាតល្អ ប៉ុន្តែក្នុងខ្លួនយើងសុទ្ធតែស្រែងចឹង គឺអត់ល្អទេ*"។



*លោក នេត សុឃាន់ នាយកសាលាបឋមសិក្សាឈើខ្លឹម*

គម្រោង HCC បានធ្វើឱ្យឥរិយាបទថ្នាក់ដឹកនាំសាលាផ្លាស់ប្តូរ ទាំងនាយករង គ្រូ គណៈកម្មការទ្រទ្រង់សាលា បណ្ណារក្ស និងសិស្ស និងបានផ្តល់ការរៀបចំថ្នាក់រៀនតាមកម្មវិធីកុមារមេត្រី។ គណៈកម្មការទ្រទ្រង់សាលាមានភាពមមាញឹកចូលរួមការងារសាលាច្រើនជាងមុន រួមមាន៖ ការមកសាលាពីព្រលឹមមុខគេ សម្អាតកញ្ចះ ចាក់ប៉ក់ខៀ ដើរត្រួតពិនិត្យបរិស្ថានសាលាគ្រប់ក្រឡុកក្រលៀតដោយមិនរង់ចាំតែលោកនាយកទេ មើលការខុសត្រូវទៅលើសុវត្ថិភាពសិស្ស ពិនិត្យតាមដានវត្តមាន និងការបង្រៀនរបស់គ្រូ ម៉ោងចូលធ្វើការរបស់បុគ្គលិក ផ្សព្វផ្សាយ និងទទួលព័ត៌មានដល់អាណាព្យាបាល និងឪពុកម្តាយ ជួយគ្រប់គ្រងថ្នាក់មត្តេយ្យ ពេលខ្លះផ្តល់ការដាស់តឿនដល់គ្រូដែលមកយឺត។

លោក យាន់ វ៉ាន់ដេត ជាប់ជាប្រធានគណៈកម្មការទ្រទ្រង់សាលាដោយការបោះឆ្នោតបានលើកឡើងថា "*ខ្ញុំពិតជាសប្បាយរីករាយខ្លាំងចំពោះការអន្តរាគមន៍ពីគម្រោង ព្រោះបានធ្វើការបណ្តុះបណ្តាលឱ្យយល់អំពីសារៈសំខាន់នៃតួនាទី និងភារកិច្ច និងបណ្តុះគំនិតឱ្យស្រឡាញ់ការអភិវឌ្ឍសាលារៀន។ សាលានេះប្រៀបបានដូចជាផ្ទះរបស់ខ្ញុំអញ្ចឹងដែរ ខ្ញុំត្រូវមើលការខុសត្រូវជាប្រចាំ ធ្វើអ្វីៗដោយតម្លាភាពជាមួយថ្នាក់ដឹកនាំសាលា និងសហគមន៍*"។



*លោក យាន់ វ៉ាន់ដេត ប្រធានគណៈកម្មការទ្រទ្រង់សាលា*

ដើម្បីធ្វើឱ្យសាលារៀនមួយមានការអភិវឌ្ឍប្រកបដោយគុណភាព គឺទាមទារឱ្យថ្នាក់ដឹកនាំសាលាប្រើបេះដូង ទើបមិនរុញរានឹងការឈ្នះឈ្នួលការងារសាលារៀន មានតម្លាភាព សមត្ថភាព និងលះបង់ចំពោះការងារអភិវឌ្ឍសាលា និងមានការឯកភាពគ្នាផ្ទៃក្នុងល្អ។ សមិទ្ធិផលគម្រោងទាំងនេះបានធ្វើឱ្យទាំងគ្រូ នាយក/រង បណ្ណារក្ស និងឪពុកម្តាយហ៊ានលះបង់ពេលវេលាផ្ទាល់ខ្លួនមកជួយធ្វើកិច្ចការសាលា ហើយបានប្តេជ្ញាចិត្តថែទាំការពាររាល់សមិទ្ធិផលទាំងនេះឱ្យស្ថិតនៅមានជានិរន្តន៍ សម្រាប់បណ្តុះបណ្តាលដល់កូនៗច្រើនជំនាន់បន្តទៀត។




# ការពង្រឹងបណ្ណាល័យស្តង់ដាសតវត្សរ៍ទី២១

នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២១ គម្រោងវិធីសាស្រ្តសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRAC III) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី **"ពង្រឹងបណ្ណាល័យស្តង់ដាសតវត្សរ៍ទី២១"** មានរយៈពេល ១ថ្ងៃនៅបន្ទប់ប្រជុំរបស់អង្គការ ខេប ដែលមានអ្នកចូលរួមសរុប ៩នាក់ជាបណ្ណារក្ស។ វគ្គនេះផ្តោតសំខាន់ទៅលើ៖ ១)-ការកំណែទម្រង់ដើម្បីរំកិលប្រព័ន្ធអប់រំកម្ពុជាឱ្យចូលទៅក្នុងសតវត្សរ៍ថ្មីមួយ ២)-បណ្តុះសមត្ថភាពលើផ្នែកគ្រប់គ្រងរដ្ឋបាល ការរៀបចំ និងការធ្វើទំនាក់ទំនងរបស់បណ្ណារក្ស ៣)-អភិវឌ្ឍន៍ចំណេះដឹង តួនាទី និងការទទួលខុសត្រូវរបស់បណ្ណារក្ស។


*សកម្មភាពប្រជុំរបស់គម្រោងត្រាក់៣ត្រូវបានធ្វើឡើងនៅការិយាល័យកណ្តាលអង្គការ ខេប។*

សិក្ខាកាមម្នាក់បានលើកឡើងថា **"ការចូលរួមវគ្គបណ្តុះបណ្តាលនេះ ខ្ញុំពិតជាសប្បាយរីករាយ ដោយទទួលបានចំណេះដឹងច្បាស់លាស់ និងការគ្រប់គ្រងបណ្ណាល័យបានល្អ និងមានប្រសិទ្ធភាព"**។

បណ្ណារក្សទទួលបានចំណេះដឹងថ្មីៗបន្ថែមទៀតលើការគ្រប់គ្រងបណ្ណាល័យដោយមានកិច្ចសហការល្អជាមួយគ្រូៗ និងសហគមន៍ ដើម្បីអភិវឌ្ឍន៍បរិស្ថានជុំវិញបណ្ណាល័យឱ្យមានភាពទាក់ទាញសិស្សឱ្យចូលមកអានសៀវភៅកាន់តែច្រើនដោយមានបណ្ណាល័យស្តង់ដាជាប្រភពចំណេះដឹងសម្រាប់សិក្សាស្រាវជ្រាវ៕

# កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់គម្រោងសៀវភៅសម្រាប់កម្ពុជា


*រូបភាពបន្ទាប់ពីកិច្ចប្រជុំប្រចាំឆ្នាំនៅវិទ្យាស្ថានជាតិអប់រំ។*

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ លោក **សៅ វណ្ណា** នាយកប្រតិបត្តិ និងលោក **ពេជ្រ សុភឿន** ប្រធានគម្រោងសៀវភៅសម្រាប់កម្ពុជា(BFC)អង្គការ ខេប បានចូលរួម និងធ្វើបទបង្ហាញនៅក្នុងការប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់គម្រោង BFC ជាមួយក្រសួងអប់រំ យុវជន និងកីឡា រួមទាំងអង្គការមូលនិធិអាស៊ី នៅវិទ្យាស្ថានជាតិអប់រំ ដោយផ្តោតសំខាន់ទៅលើ៖ ១)-ប្រវត្តិនៃការចុះអនុស្សរណៈយោគយល់ ២)-ផែនការយុទ្ធសាស្រ្ត ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ៣)-ការអនុវត្តសកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៩-២០២១ ៤)-បញ្ហាប្រឈម ៥)-សំនួរ ពិភាក្សា ៦)-ស្នើសុំការអន្តរាគមន៍។ លទ្ធផលប្រជុំត្រូវបានធ្វើការស្នើសុំឱ្យមានការផ្លាស់ប្តូរផែនការយុទ្ធសាស្រ្តសម្រាប់ឆ្នាំ២០២១៕




# សិក្ខាសាលាស្តីពី "ការអប់រំបំណិនជីវិតមូលដ្ឋាន"

គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK) ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងសហប្រតិបត្តិដោយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប/KAPE) រួមជាមួយអង្គការជាដៃគូចំនួនបីផ្សេងទៀត ដូចជា អង្គការវើវើល (WeWorld) អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) និងអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) បានរៀបចំវគ្គសិក្ខាសាលាស្តីពី **"ការអប់រំបំណិនជីវិតមូលដ្ឋាន"** ចាប់ពីខែមករាដល់ ខែកុម្ភៈ ឆ្នាំ២០២១ ទៅដល់នាយក នាយករង និងគ្រូទទួលបន្ទុកបំណិនជីវិតចំនួន ៦៤នាក់ (ស្រី២៦នាក់) មកពីសាលារៀនគោលដៅក្នុងស្រុកត្បូងឃ្មុំ និងក្រូចឆ្មារក្នុងខេត្តត្បូងឃ្មុំ។

គម្រោង SEEK បង្កើតឡើងដើម្បីបំពេញនូវសិទ្ធិសេដ្ឋកិច្ច និងសង្គមរបស់យុវជន ជាពិសេសការយកចិត្តទុកដាក់ទៅលើស្ត្រីមកពីសហគមន៍ជនជាតិចាម តាមរយៈទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្ន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារដែលសមរម្យនាពេលអនាគត។

នៅថ្ងៃទី១ សិក្ខាកាមបានស្វែងយល់ពីកម្មវិធីសិក្សា និងវត្ថុបំណងក្នុងសៀវភៅអប់រំបំណិនជីវិតតាមមូលដ្ឋានដែលផលិតដោយក្រសួងអប់រំ យុវជន និងកីឡា។ ទន្ទឹមនឹងនេះ សិក្ខាកាមបានជ្រើសរើសមេរៀនពីក្នុងសៀវភៅបំណិនជីវិត ដើម្បីបង្រៀនក្នុងថ្នាក់ដោយអនុវត្តសកម្មភាពបែបចូលរួម និងសកម្មភាពពិភាក្សាជាក្រុមតូចៗ។

នៅថ្ងៃទី២ សិក្ខាកាមទទួលបានចំណេះដឹងពីការអប់រំបំណិនជីវិតបច្ចេកទេស (ការបណ្តុះកូនឈើ) និងអនុវត្តផ្ទាល់ពីការសាកមែក តភ្ជែក និងការកែច្នៃសំបកកង់ឡានដាំផ្កា។ សាលានីមួយៗបានធ្វើផែនការបង្រៀនបំណិនជីវិតតាមសាលារៀងៗខ្លួន។ ការបំប៉នមេរៀនបំណិនជីវិតតាមសាលារៀននឹងប្រព្រឹត្តទៅនៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០២១។

សិក្ខាសាលាបានដំណើរការទៅដោយជោគជ័យ និងមានកិច្ចសហការល្អ លទ្ធផលធ្វើតេស្តសិក្ខាកាមបន្ទាប់ពីចូលរួមសិក្ខាសាលាមានចំនួន ៧០% បានយល់ដឹងច្បាស់លាស់ល្អពីការអប់រំបំណិនជីវិតមូលដ្ឋាន បើប្រៀបធៀបនឹងតេស្តមុនពេលសិក្ខាសាលា គឺមានចំនួនតែ ៣០%ប៉ុណ្ណោះ៕



*សកម្មភាពលោកគ្រូអ្នកគ្រូពិភាក្សាជាក្រុមតូចៗផ្តោតលើបំណិនជីវិតមូលដ្ឋានដែលបានដកស្រង់ចេញពីសៀវភៅផ្ទ។*




# យើងធ្វើការងារជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពសម្រាប់កិច្ចគាំទ្រចំពោះបញ្ហាប្រឈមលើការសិក្សារបស់សិស្សកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩

នៅក្នុងខែធ្នូ ឆ្នាំ២០២០ អង្គការ ខេប បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរយៈពេលមួយឆ្នាំ ជាមួយអង្គការ យូនីសេហ្វ ដើម្បីគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងការឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់ក្នុងបរិបទជំងឺកូវីដ-១៩ ក្រោមកម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩ គាំទ្រដោយភាពជាដៃគូសកលដើម្បីការអប់រំ (CERRP)។

អង្គការ ខេប មានតួនាទីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់នាយកដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានសមាសភាគសំខាន់ៗពីរ៖

១)-ការបន្តការសិក្សាពីចម្ងាយ (ជាអាទិភាពក្នុងពេលបិទសាលា)៖ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការទទួលបានការសិក្សា និងគុណភាពនៃសម្ភារៈសិក្សាពីចម្ងាយទាំងអស់ ដែលផលិតដោយក្រសួងអប់រំ យុវជន និងកីឡា (វីដេអូ និងសន្លឹកកិច្ចការ)។

២)-ការសម្របសម្រួលការសិក្សាពីចម្ងាយ (នៅពេលសាលារៀនបើកដំណើរការ)៖ សាលានឹងទទួលបានកញ្ចប់ឯកសារសិក្សាបំប៉នបន្ថែម ដើម្បីជួយដល់សិស្សក្នុងការពង្រឹងសមត្ថភាពគោលលើមុខវិជ្ជាគណិតវិទ្យា និងមុខវិជ្ជាភាសាខ្មែរ ដើម្បីអាចឱ្យពួកគេសិក្សាបន្តនៅថ្នាក់បន្ទាប់នាពេលខាងមុខ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១៣ អយក.ឯសណន

**សេចក្តីណែនាំប្រតិបត្តិ**
**ស្តីពី**
**ការបំប៉នបន្ថែមដល់សិស្សរៀនយឺត នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ**

ដើម្បីធានាបានថា សិស្សរៀនយឺតមានមូលដ្ឋានសមស្របសម្រាប់ការបន្តការសិក្សានៅថ្នាក់បន្ទាប់ទៀត ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់សាលារៀន ស្តីពីការបំប៉នបន្ថែមដល់សិស្សរៀនយឺត នៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដូចខាងក្រោម៖

**១- ការធ្វើតេស្តវាយតម្លៃសមត្ថភាពសិស្ស**

- **គោលបំណង៖** ដើម្បីវាយតម្លៃសមត្ថភាពសិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ព្រមទាំងជួយគ្រូបង្រៀនឱ្យវាយតម្លៃបានត្រឹមត្រូវ និងកំណត់បាននូវខ្លឹមសារមេរៀនដែលសិស្សរៀនយឺត។
- **ពេលវេលា៖** ប្រចាំខែនីមួយៗ។
- **សិស្សគោលដៅ៖** សិស្សានុសិស្សទាំងអស់ពីថ្នាក់ទី២ ដល់ទី៦
- **គណៈគ្រប់គ្រង និងគ្រូបង្រៀនត្រូវ៖**
  - គណៈគ្រប់គ្រង ត្រូវដឹកនាំនិងគ្រប់គ្រងលើការងារតេស្តវាយតម្លៃសមត្ថភាពសិស្ស
  - គ្រូបង្រៀនរៀបចំផលិតតេស្តសិស្ស លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ឬប្រើប្រាស់ឧបករណ៍វាយតម្លៃដើម្បីធ្វើការវិនិច្ឆ័យបញ្ហាសិស្ស ដែលបង្កើតឡើងដោយក្រសួង (កញ្ចប់ឯកសារទី១ ស្តីពីការបំប៉នបន្ថែម ជូនភ្ជាប់)
  - គ្រូបង្រៀនដឹកនាំធ្វើតេស្តសិស្សទៅតាមគោលការណ៍នៃការប្រឡង
  - គ្រូបង្រៀនកែកិច្ចការសិស្ស និងបញ្ចូលពិន្ទុក្នុងកុំព្យូទ័រ ឬ បញ្ជីលទ្ធផលតេស្ត
  - គ្រូបង្រៀនរៀបចំបញ្ជីឈ្មោះសិស្សរៀនយឺត ដោយបញ្ជាក់ខ្លឹមសារមេរៀនដែលរៀនយឺតទាំងមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ដោយមានការឯកភាពពីគណៈគ្រប់គ្រងសាលា
  - គ្រូបង្រៀនរៀបចំផែនការរំលស់សិស្សរៀនយឺតប្រចាំខែ និងប្រចាំត្រីមាស ដោយមានការឯកភាពពីគណៈគ្រប់គ្រងសាលា។

**២- វិធីសាស្ត្របំប៉នបន្ថែមដល់សិស្សរៀនយឺត**

ផ្អែកតាមខ្លឹមសារមេរៀនដែលសិស្សម្នាក់ៗរៀនយឺត និងតាមផែនការរំលស់សិស្សរៀនយឺត លោកគ្រូ អ្នកគ្រូ ត្រូវអនុវត្តការបង្រៀននិងរៀនតាមវិធីសាស្ត្រដូចខាងក្រោម៖

1

info@moeys.gov.kh / administration@moeys.gov.kh www.moeys.gov.kh

ដំណាក់កាលចាប់ផ្តើមគម្រោងបានចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០២១ អង្គការ ខេប បានផ្តល់អាទិភាពលើកិច្ចគាំទ្រដល់នាយកដ្ឋានបឋមសិក្សានៅក្នុងសមាសភាគទី ២ គឺការសិក្សាបំប៉នបន្ថែម។ អង្គការ ខេប ទទួលបន្ទុកបង្កើតកញ្ចប់ឯកសារមុខវិជ្ជាភាសាខ្មែរ ដោយសហការជាមួយអង្គការដៃគូ VVOB ដែលទទួលបន្ទុកបង្កើតកញ្ចប់ឯកសារមុខវិជ្ជាគណិតវិទ្យា។ ក្រុមការងារគម្រោងបានគាំទ្រដល់នាយកដ្ឋានបឋមសិក្សា (PED) ដើម្បីចេញសេចក្តីណែនាំប្រតិបត្តិលេខ១៣ ដែលណែនាំទៅដល់សាលាបឋមសិក្សា ក្នុងការអនុវត្តលើកិច្ចគាំទ្រការងារបំប៉នបន្ថែម

ដោយកំណត់យក៣ថ្ងៃព្រហស្បតិ៍ក្នុងមួយខែ បូករួមទាំងម៉ោងបង្រៀនបន្ថែម ដែលចាំបាច់ប្រើក្នុងអំឡុងម៉ោងបង្រៀនធម្មតា ម៉ោងសម្រាក និងកិច្ចការផ្ទះ។ យើងសន្មត់ជាទូទៅបានថា សិស្សទាំងអស់នឹងត្រូវការការគាំទ្របន្ថែមលើការសិក្សាមួយចំនួននៅពេលពួកគេវិលត្រឡប់ទៅសាលារៀនវិញ ដើម្បីស្រោចស្រង់ការសិក្សាដែលបានខកខាន។ នៅជំហានបន្ទាប់ អង្គការ ខេប និងអង្គការ VVOB បានកំណត់ខ្លឹមសារកញ្ចប់ឯកសារសិក្សាបំប៉នបន្ថែម ដោយបន្ថែមសមត្ថភាពគោលលើមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាគណិតវិទ្យា ដោយចាត់ទុកចំណេះទាំងនេះជាចំណេះដឹងគ្រឹះ និងចំណេះដឹងគោល ដែលសិស្សទាំងអស់ត្រូវចេះ ដើម្បីអាចរៀនទៅមុខទៀតបាន ហើយអង្គការទាំងពីរក៏គាំទ្រដល់ការបង្កើត និងការចែកចាយនូវកញ្ចប់ឯកសារសិក្សាបំប៉នបន្ថែម តាមរយៈមធ្យោបាយជាផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា រួម មានៈ តេឡេក្រាម (Telegram) និងវេទិកាសិក្សាតាមអេឡិចត្រូនិក (https://elearning.moeys.gov.kh/rean/)។

ដោយសារតែសាលារៀននៅបន្តបិទ ក្រោយការផ្ទុះឡើងនូវព្រឹត្តិការណ៍ ២០កុម្ភៈ អង្គការ ខេប បានចាប់ផ្តើមធ្វើការជាបន្ទាន់លើសមាសភាគផ្សេងទៀតជាមួយវិទ្យាស្ថានបើកទូលាយ (OI) ដែលជាអង្គការដៃគូ ដើម្បីលើកកម្ពស់ការទទួលបានការសិក្សា និងគុណភាពនៃធនធានសិក្សាពីចម្ងាយដោយមាន (ទាំងសន្លឹកកិច្ចការ និងឌីជីថល)។ បច្ចុប្បន្ននេះ វិទ្យាស្ថានបើកទូលាយ និងអង្គការ ខេប បានកំពុងគាំទ្រដល់នាយកដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងអស់ មានដូចជា (នាយកដ្ឋានបឋមសិក្សា (PED) នាយកដ្ឋានអប់រំកុមារតូច(ECED) នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (DGSE) នាយកដ្ឋានអប់រំពិសេស/វិទ្យាស្ថានជាតិអប់រំពិសេស(SED/NISE)) ដើម្បីកំណត់ និងរៀបចំសម្ភារៈសិក្សាពីចម្ងាយ ដាក់បញ្ចូលទៅក្នុងវេទិការបស់ក្រសួងអប់រំ យុវជន និងកីឡា។ អង្គការ ខេប ក៏បានគាំទ្រដល់នាយកដ្ឋានបច្ចេកទេសក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់គុណភាពការសិក្សាតាមសន្លឹកកិច្ចការ និងសម្ភារៈសិក្សាបែបឌីជីថលនាពេលបច្ចុប្បន្ន និងទៅអនាគត។ អង្គការ ខេប ក៏កំពុងសម្របសម្រួលជាមួយមជ្ឈមណ្ឌលសិក្សាពីចម្ងាយ និងឌីជីថលផងដែរ ដើម្បីធានាដល់សុខុដុមនីយកម្មលើកិច្ចខិតខំប្រឹងប្រែងទាំងមូលក្នុងការលើកកម្ពស់លើការសិក្សាពីចម្ងាយតាមប្រព័ន្ធឌីជីថល។ គម្រោងរំពឹងថា នៅខែមិថុនា ឆ្នាំ២០២១ ធនធានសិក្សាពីចម្ងាយទាំងអស់សម្រាប់កម្រិតបឋមនឹងត្រូវបានរៀបចំរួចរាល់ ហើយអាចរកបាននៅក្នុងគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា រួមទាំងឯកសារសិក្សាបន្ថែមនានាដែលត្រូវបានក្រសួងអប់រំ យុវជន និងកីឡាអនុម័ត៕









# ជំរុញសិស្សានុសិស្សបន្តអនុវត្តន៍ការសិក្សាពីចម្ងាយ (បែបនិម្មិត)

កម្មវិធីរបស់អង្គការ ខេប នៅតាមសាលារៀនគោលដៅជាច្រើនបានកំពុងព្យាយាមដោះស្រាយបញ្ហាប្រឈមនានាដែលប៉ះពាល់ដោយសារការរីករាលដាលជំងឺកូវីដ-១៩។ អង្គការ ខេប បានធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការផ្សព្វផ្សាយសន្លឹកកិច្ចការស្វ័យសិក្សា ដើម្បីបន្តការគាំទ្រដល់ការសិក្សារបស់សិស្សានុសិស្ស។ ទន្ទឹមនឹងនោះ អង្គការ ខេប ក៏បានប្រើប្រាស់ហិរញ្ញប្បទានម្ចាស់ជំនួយបង្កើតកញ្ចប់ឧបករណ៍ការពារជំងឺកូវីដ-១៩ រួមមាន៖ បរិក្ខារអនាម័យ (ម៉ាស់ អាល់កុល) និងល្បែងសិក្សាដែលឪពុកម្តាយអាចប្រើប្រាស់បានដើម្បីគាំទ្រដល់ការសិក្សានៅតាមផ្ទះ។

អង្គការ ខេប បានធ្វើការងារសម្របសម្រួលជាមួយសាលាគោលដៅឱ្យរក្សាបណ្ណាល័យបើកដំណើរការដើម្បីឱ្យឪពុកម្តាយសិស្សអាចមកខ្ចីសៀវភៅ និងល្បែងសិក្សាឱ្យកូនៗពួកគាត់បានប្រើប្រាស់ក្នុងការសិក្សានៅផ្ទះបាន។

ចំពោះការសិក្សាតាមអនឡាញវិញ អង្គការ ខេប បានកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលអប់រំពីចម្ងាយ និងឌីជីថល នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ធ្វើឱ្យសកម្មភាពសិក្សានៅសាលារៀនជំនាន់ថ្មីដំណើរការទៅមុខតាមប្រព័ន្ធអនឡាញ។ ក្នុងន័យនេះដែរ អង្គការ ខេប បានជួយសាលារៀនជាច្រើនក្នុងការឈ្នួសឈ្នួលសកម្មភាពសិក្សាជាទម្រង់និម្មិត (ការសិក្សាពីចម្ងាយ ឬតាមអនឡាញ) ដោយផ្តោតខ្លាំងទៅលើការផលិតវីដេអូមេរៀន។ វីដេអូប្រមាណ ៤.១៨០ក្លីបត្រូវបានផលិតដោយសាលារៀនជំនាន់ថ្មីសម្រាប់ចែកចាយទៅមជ្ឈមណ្ឌលអប់រំពីចម្ងាយ និងឌីជីថល (CDDE)។

អង្គការ ខេប ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូនីសេហ្វជ្រើសរើសឱ្យជួយធ្វើការងារបច្ចេកទេសគាំទ្រដល់នាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សា ចំណេះដឹងទូទៅរបស់ក្រសួង ក្នុងការបង្កើតសន្លឹកកិច្ចការសិក្សាបន្ត និងកម្មវិធីបង្រៀនបំប៉នបន្ថែមដែលជាផ្នែកមួយរបស់កម្មវិធី GPE ឈ្មោះថា កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ ១៩។ អង្គការ ខេប មានតួនាទីផ្តោតលើការជួយសម្របសម្រួលជាមួយម្ចាស់ជំនួយព្រមទាំងការគាំទ្របច្ចេកទេសដល់នាយកដ្ឋាននីមួយៗរបស់ក្រសួងអប់រំ យុវជន និងកីឡា។ បច្ចុប្បន្ននេះ គម្រោងរបស់អង្គការ ខេប ចំនួន ១៣កំពុងប្រតិបត្តិការនៅក្នុងតំបន់គោលដៅដែលយកចិត្តទុកដាក់លើការសិក្សាពីចម្ងាយ៕




*សកម្មភាពសិស្សនៅសាលារៀនជំនាន់ថ្មី សាលាបឋមសិក្សាអង្គរបាន បានប្រើប្រាស់កម្មវិធី Google Meet សម្រាប់សិក្សាបែបនិម្មិត ជាវិធីដែលមានសុវត្ថិភាពក្នុងការចូលរួមប្រយុទ្ធប្រឆាំងនឹងការឆ្លងរីករាលដាលជំងឺកូវីដ-១៩។ សាលាបឋមសិក្សាអង្គរបានជាសាលារៀនគោលដៅមួយក្នុងចំណោមសាលារៀនគោលដៅជាច្រើនទៀតនៃកម្មវិធីសាលារៀនជំនាន់ថ្មីរបស់អង្គការ ខេប។*





# បុគ្គលិកធនាគារ អេប៊ីអេ/ABA ឧបត្ថម្ភដបដាក់ទឹកដល់អង្គការ ខេប

អង្គការ ខេប សូមសម្តែងនូវការអរគុណចំពោះការស្ម័គ្រចិត្តឧបត្ថម្ភដបដាក់ទឹកចំនួន ៧០ដបរបស់បុគ្គលិកធនាគារ អេប៊ីអេ/ABA សាខាក្រុងកំពង់ចាម កាលពីថ្ងៃចន្ទ ១១កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ដើម្បីឱ្យអង្គការ ខេប រៀបចំចែកជូនដល់កុមារក្រីក្រនៅនៅក្នុងតំបន់គោលដៅរបស់គម្រោង។ អង្គការ ខេប សូមជូនពរដល់បុគ្គលិកធនាគារ អេប៊ីអេ/ABA ទទួលបាននូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីអាក់ខានឡើយ៕



*លោក បូ សម្បត្តិ ជានាយកគ្រប់គ្រងហិរញ្ញវត្ថុ និងបុគ្គលិកតំណាងឱ្យអង្គការ ខេប ដើម្បីទទួលយកដបដាក់ទឹកពីតំណាងធនាគារ ABA សម្រាប់ចែកជូនសិស្សគោលដៅ។*

# កិច្ចប្រជុំប្រចាំខែរបស់គម្រោងកុមារកម្ពុជារីករាយ (HCC)



*លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប បានចូលរួមកិច្ចប្រជុំប្រចាំខែកុម្ភៈ ក្នុងគម្រោងកុមារកម្ពុជារីករាយ (HCC) នៅការិយាល័យកណ្តាល ក្រុងកំពង់ចាម។*

នៅថ្ងៃទី២៤-២៦ ខែកុម្ភៈ ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយ (HCC) ក្រោមជំនួយហិរញ្ញប្បទានពីមូលនិធិ គីនឆាន់ ស្វីហ្វទុង និងប្រតិបត្តិដោយអង្គការ ខេប បានរៀបចំកិច្ចប្រជុំប្រចាំខែនៅសាលប្រជុំរបស់អង្គការ ខេប ដោយមានបុគ្គលិកគម្រោងចូលរួមទាំងអស់ចំនួន ១៥នាក់ និងអ្នកពាក់ព័ន្ធផ្សេងទៀត។ កិច្ចប្រជុំនេះមានគោលបំណង៖ ១)-បង្ហាញវឌ្ឍនភាពការអនុវត្តសកម្មភាពគម្រោង ២)-ពង្រឹងយន្តការធ្វើការងារបណ្ណារក្ស និងពង្រីកសកម្មភាពក្នុងបណ្ណាល័យ ៣)-យល់កាន់តែច្បាស់ពីរបៀបជួយគាំទ្រគ្រូបង្រៀន ជាពិសេសសង្កេត និងផ្តល់ព័ត៌មានត្រឡប់ ៤)-ត្រៀមរៀបចំយន្តការគម្រោងថ្នាក់ជាតិ និងក្រោមជាតិ ៥)-រៀបចំផែនការបន្ត។ ការពិភាក្សាផ្តោតអំពីទម្រង់តាមដាន និងវាយតម្លៃសិស្សធំជួយសិស្សតូច ការរៀបចំសកម្មភាពក្នុងបណ្ណាល័យ ទម្រង់របាយការណ៍របស់បណ្ណារក្ស និងទម្រង់វាយតម្លៃបណ្ណាល័យសម្រាប់គម្រោង ការចុះសង្កេតគ្រូបង្រៀន ឧបករណ៍សង្កេតគ្រូបង្រៀន ឧបករណ៍ត្រួតពិនិត្យ និងថែទាំសាលារៀន យន្តការតាមដាន និងការត្រួតពិនិត្យសកម្មភាពសាលារៀន ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពគម្រោង ព្រមទាំងរៀបចំផែនការសម្រាប់គម្រោងខែបន្ទាប់។

កិច្ចប្រជុំប្រចាំខែនេះ បានពង្រឹងសមត្ថភាពមន្ត្រីគម្រោងលើការអនុវត្តន៍កម្មវិធីឱ្យកាន់តែល្អប្រសើរ និងបានយល់ដឹងពីយន្តការសំខាន់ៗដើម្បីជួយសិស្សដែលមានតម្រូវការបន្ថែម ព្រមទាំងណែនាំគ្រូបង្រៀនអនុវត្តន៍កម្មវិធីឱ្យត្រូវគោលដៅរបស់គម្រោងប្រកបដោយគុណភាព តាមរយៈការចុះត្រួតពិនិត្យតាមដានតាមសាលារៀនគោលដៅនីមួយៗ៕



# កុំរស់សង្ឃឹម !



ប្រភពរូបភាព #Pinterest

ជីវិតដែលឆ្លងកាត់រឿងរ៉ាវមិនសមប្រកបឧបសគ្គ និងបញ្ហា វាមិនត្រឹមតែធ្វើឱ្យយើងរឹងមាំតែប៉ុណ្ណោះទេ ប៉ុន្តែវាជាមេរៀន និងជាការចងចាំដ៏ល្អបំផុត។ ពេលខ្លះអង្គុយគិតពីរឿងចាស់ៗទាំងអស់នោះ វាអាចធ្វើឱ្យអ្នកក្រៀមក្រំ សប្បាយចិត្ត និងអស់សំណើចដោយមិននឹកស្មានថាអ្នកក្លាយជាអ្នកទៅថ្ងៃនេះដោយសាររឿងដែលធ្លាប់បានឆ្លងកាត់កន្លងមក។ ឱ្យតែអ្នកមានការតាំងចិត្ត និងមានគោលដៅមួយច្បាស់លាស់ រួមចាប់ផ្ដើមធ្វើវា គឺធ្វើដោយមិនរង់ចាំថ្ងៃស្អែក នោះគ្រប់យ៉ាងនឹងបានល្អប្រសើរជាងពេលនេះ។ មនុស្សគ្រប់គ្នាគប្បីរៀនរស់នៅជាមួយនឹងការពិតថាជីវិត គឺជាការតស៊ូ ការលះបង់ ការអត់ធ្មត់ និងក្លាហានព្រមទទួលយកការផ្លាស់ប្ដូរ ហើយរីករាយនឹងរឿងរ៉ាវថ្មីៗ។ ទោះបីជាស្ថិតក្នុងស្ថានភាពអាក្រក់បែបណាក្ដី បើយើងមិនគេចវេស ដោះសា ហើយហ៊ានប្រឈមមុខ នោះគ្មានអ្វីដែលថាមិនអាចទៅរួចឡើយ។ បើយើងម្នាក់ៗខ្លាចការលំបាក តើធ្វើដូចម្ដេចអាចរកឃើញនូវដំណោះស្រាយទាំងនោះបាន? ទោះបីជាមានឧបសគ្គជាច្រើនកំពុងរង់ចាំ ប៉ុន្តែយើងក៏កំពុងដើរទៅមុខ គឺដើរនៅលើផ្លូវដែលខ្លួនស្រលាញ់ ដើរដោយភាពជឿជាក់ ហើយមិនព្រមចុះចាញ់ជាដាច់ខាត តស៊ូរហូតដល់ដំណាក់កាលនៃ វិនាទីចុងក្រោយ៕

*(ដកស្រង់ចេញពីសៀវភៅមនុស្សខ្មៅ)*

# ចុងក្រោយអ្នកត្រូវធ្វើការសម្រេចចិត្ត

មនុស្សម្នាក់ៗតែងតែធ្វើការសម្រេចចិត្តជាប្រចាំ តូចក្ដី ធំក្ដី ហើយវាតែងមានហេតុផលដែលអ្នកត្រូវធ្វើការសម្រេចចិត្តក្នុងស្ថានភាពបែបណាមួយ អ្នកនឹងទទួលបានផលពីការសម្រេចចិត្តនោះនៅថ្ងៃមួយ។ ចូររីករាយនឹងទទួលស្គាល់ការពិតនូវអ្វីដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងពេញចិត្តនូវអ្វីដែលអ្នកបានសម្រេចចិត្ត។ កុំខ្លាចក្នុងការធ្វើខុស ត្រូវមានភាពក្លាហាន ហ៊ានប្រឈមមុខ និងមានការទទួលខុសត្រូវចំពោះសកម្មភាពដែលអ្នកបានធ្វើ។ ពេលអ្នកចង់សម្រេចចិត្តក្នុងការធ្វើអ្វីមួយ អ្នកតែងតែសុំយោបល់ពីមនុស្សដែលអ្នកទុកចិត្ត ប៉ុន្តែកាលៈទេសៈខ្លះ បើពួកគេមិនយល់ស្របនឹងការសម្រេចចិត្តនោះ អ្នកក៏មិនសប្បាយចិត្តដែរ។ ការសុំយោបល់ពីមនុស្សក្បែរខ្លួនវាជារឿងល្អ ពីព្រោះគំនិតច្រើនអាចស្វែងរកមធ្យោបាយល្អក្នុងដោះស្រាយ តែចុងក្រោយអ្នកតែម្នាក់គត់ជាសម្រេចចិត្ត។ ដូច្នេះពេលអ្នកចង់ធ្វើអ្វីក៏ធ្វើទៅ គ្មានអីត្រូវខ្លាចនោះទេ! ផ្ទុយទៅវិញ បើអ្នកសម្រេចចិត្តធ្វើតាមនរណាម្នាក់ ពេលទទួលបានលទ្ធផលល្អ នោះអ្នកនឹងដឹងគុណដល់ពួកគេ តែបើខុសវិញ អ្នកនឹងស្ដាយក្រោយ និងនៅតែមិនអស់ចិត្តថាហេតុអ្វីមិនធ្វើតាមចិត្តខ្លួនឯង។ អ្នកជាមនុស្សដំបូងដែលទទួលខុសត្រូវជាមួយបញ្ហាដែលបានកើតឡើង ហើយអ្នកនឹងស្គាល់មនុស្សស្រឡាញ់អ្នក ចាំជួយអ្នក គាំទ្រអ្នកនៅពេលនោះឯង។ លទ្ធផលនឹងកើតឡើងរាល់ពេលអ្នកសម្រេចចិត្តធ្វើអ្វីមួយ រាល់សកម្មភាព សុទ្ធតែមានលទ្ធផលទាំងអស់៕



ប្រភពរូបភាព #Pinterest

*(ដកស្រង់ចេញពីសៀវភៅខ្យល់ដង្ហើម)*





# តម្លៃនៃអំណាន

(បទ ពាក្យប្រាំពីរ)

១ អានច្រើនចេះច្រើនកើនគំនិត
មើលឃើញពិភពលោកអស្ចារ្យ
ប្រាជ្ញាចេះគិតពិចារណា
បញ្ចេញវាចាល្អប្រពៃ។
២ បណ្តុះឱ្យខ្លួនជាមនុស្សល្អ
អានព្រឹកអានយប់អានទាំងថ្ងៃ
ប្រសើរបវរប្រសើរក្រៃ
លៃលកកែច្នៃចម្រើនណាស់។
៣ បណ្តុះគំនិតល្អៗច្រើន
បញ្ញាថ្មីៗគរស្តេកស្តះ
បញ្ញាចម្រើនកើនមិនខ្វះ
តម្រាល្អល្អះតរៀងទៅ។
៤ ហេតុនេះចូរយើងឧស្សាហ៍អាន
មិនថាការសែតឬសៀវភៅ
សៀវភៅអំណានដែលត្រឹមត្រូវ
ត្រិះរកខុសត្រូវត្រង់ណាមួយ។
៥ យើងនឹងជាជនមានតម្លៃ
ខំកសាងជាតិ និងលើកស្ទួយ
ក្នុងសង្គមក្រៃដែលជាត្រួយ
កិត្តិយសជាត្រួយដ៏ថ្លៃថ្លា។
៦ ម្យ៉ាងយើងយុវជនយុវតី
តាំងចិត្តតស៊ូ និងរក្សា
មិនត្រូវខ្លាចភ័យឬអា
ប្រកបចរិយាដោយសមរម្យ។
៧ សង្គមពោរពេញដោយគំនិត
ចេះឱនលំទោនតាមក្រឹត្យក្រម
មនុស្សចេះគិតវាងវៃសម
ទូន្មានអប់រំចិត្តមនុស្សល្អ។
៨ ប្រទេសរុងរឿងរីកចម្រើន
ប្រជាជនចូលរួមត្រេកអរ
ប្រាជ្ញាមនុស្សកើនបានបវរ
អបអរសាទរយ៉ាងអស្ចារ្យ។
៩ កុំឱ្យពុកម៉ែអស់សង្ឃឹម
ឃើញកូនពូកែមានប្រាជ្ញា
ឱ្យគាត់ញញឹមមុខស្រស់ថ្លា
នាំជាតិគ្រួសារថ្កើងបវរ។
១០ ចុងក្រោយចូរកូនចងចាំថា
ប្រយោជន៍ខ្លាំងណាស់អានអក្សរ
ចំណាំចំណារឱ្យបានល្អ
ជួយយើងលែងក្រល្អរុងរឿង។



និពន្ធដោយយុវសិស្ស ញឹម សុខវិសាល
ជាសិស្សថ្នាក់ ទី១១ នៅសាលារៀនជំនាន់ថ្មី
វិទ្យាល័យព្រះស៊ីសុវត្ថិ

*ផៅឡូ ហ្វ្រេរី បានលើកឡើងថា "ការអប់រំមិនអាចផ្លាស់ប្តូរពិភពលោកទាំងមូលបានទេ តែការអប់រំផ្លាស់ប្តូរមនុស្ស ហើយមនុស្សផ្លាស់ប្តូរពិភពលោក"។*

***"Education does not change the world. Education changes people. People changes the world," Paulo Freire.***

# មតិអ្នកអាន



លោក រុន រស្មី ជាអតីតសិស្សអាហារូបករណ៍អង្គការ ខេប និង បច្ចុប្បន្នជាគ្រូបង្រៀននៅសាលាបឋមសិក្សាអូរឫស្សី បានមានប្រសាសន៍ថា *"គម្រោងរបស់អង្គការ ខេប បានចូលរួមចំណែកដល់ការផ្លាស់ប្តូរក្នុងវិស័យអប់រំនៅកម្ពុជាតាមរយៈសកម្មភាពជាច្រើន ដូចជា៣ជួយផ្តល់ជាសម្ភារៈសិក្សាដល់សិស្សានុសិស្សនៅថ្នាក់អនុវិទ្យាល័យ វិទ្យាល័យ និងបានផ្តល់អាហារូបករណ៍បន្តការសិក្សាថ្នាក់សាកលវិទ្យាល័យថែមទៀតផង។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺគម្រោងអប់រំកុមារី (GEI) របស់អង្គការ ខេបបានជួយផ្តត់ផ្គង់ថវិកាសម្រាប់គរុសិស្សក្រីក្រ ដែលកំពុងតែសិក្សានៅសាលាគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យ។ ខ្ញុំសូមអរគុណទៅដល់គម្រោង GEI ដែលជួយគាំទ្រសម្រាប់ឱ្យបន្តការសិក្សារហូតដល់ពេលខ្ញុំបានបញ្ចប់ការសិក្សាពីសាលាគរុកោសល្យនេះផងដែរ"។*



# វិធានការ ៣កុំ ៣ការពារ

(បទ ពាក្យប្រាំពីរ)

១. មេរោគកូវីដដប់ប្រាំបួន    បានបង្ហាញខ្លួនក្នុងសហគមន៍
ម្ដេកុម្ភៈជួបគ្នាជំនុំ    បង្កគ្រោះធំដល់កម្ពុជា។
២. នៅតាមខេត្តក្រុងរាជធានី    ភិតភ័យជាទីដល់ប្រជា
ពលរដ្ឋ រដ្ឋាជនគ្រប់គ្នា    បាត់បង់ការងារខ្វះថវិកា។
៣. ផ្អាកការរៀនបណ្ដោះអាសន្ន    នៅគ្រប់តំបន់តាមសាលា
រដ្ឋ ឯកជនគ្រឹះស្ថានសិក្សា    ផ្អាកគ្រប់សាខានៃកម្ពុជា។
៤. ទូទាំងប្រទេសផ្អាកជួបជុំ    រក្សាបីកុំបីការពារ
រក្សាគម្លាតគ្រប់អង្គា    កូរ៉ូណាវាចៀសឆ្ងាយខ្លួន។
៥. បុគ្គលគ្រប់រូបត្រូវប្រយ័ត្ន    ជុំគ្នាផ្ដាច់កាត់គោរពក្បួន
ពាក់ម៉ាស់ការពារឱ្យខ្ជាប់ខ្លួន    ជួយការពារខ្លួនផុតគ្រោះភ័យ។
៦. ត្រូវមានអាល់កុលនិងសាប៊ូ    អ្នកត្រូវគិតគូរសម្អាតដៃ
លាងដៃញឹកញាប់រៀងរាល់ថ្ងៃ    កូវីដនឹងក្ស័យបាត់សង្ខារ។
៧. គម្លាតសុវត្ថិភាពនៃសង្គម    ឃ្លាតគ្នាមិនជុំជួយរក្សា
មួយម៉ែត្រកន្លះតាមសាស្ត្រា    សុខាភិបាលបានជម្រាប។
៨. កុំទៅកន្លែងមានមនុស្សច្រើន    ព្រោះអាចបង្កើនសមត្ថភាព
មេរោគចម្លែងអាចចូលជ្រៀប    បង្កជាភាពកាយគ្រាំគ្រា។
៩. កុំចេញទៅក្រៅឬប៉ះពាល់    ស្វាគមន៍ដោយផ្ទាល់ចាប់ដៃគ្នា
ការឱបការថើបត្រូវការពារ    ត្រូវប្ដូរមកជាសំពះម្ដង។
១០. កុំទៅកន្លែងដែលបិទជិត    រោគអាចរួមរឹតតាមកាយផង
រកកន្លែងខ្យល់ឱ្យហួត់ហួង    មេរោគមិនឆ្លងដល់ដង្ហើម។
១១. ដូច្នេះត្រូវចាំកុំប្រហែស    ត្រូវមានចំណេះជាអ្នកផ្ដើម
ក្អក ឬកណ្ដាស់ខ្ទប់ជាដើម    គ្រប់គ្នាផ្ទុងផ្ដើមចេះការពារ។



និពន្ធដោយយុវសិស្ស **ថា លីដា**
ជាសិស្សថ្នាក់ទី១០ នៅសាលារៀនជំនាន់ថ្មី
វិទ្យាល័យ សម្ដេចហ៊ុន សែន ពាមជីកង

វិចទ័រ ហ៊ូហ្គោ "លំបាកដោយមានប្រាជ្ញា ប្រសើរជាងការសប្បាយដោយភាពល្ងង់ខ្លៅ"។
*"An intelligent hell would be better than a stupid paradise," Victor Hugo.*

# មតិអ្នកអាន



លោក គ្រូ ហេង សុខុម ជានាយកសាលា នៅវិទ្យាល័យក្រុមព្រះមហាលាភ *"គម្រោងរបស់អង្គការ ខេប បានជួយច្រើនដល់វិស័យអប់រំនៅប្រទេសកម្ពុជាយើង ទាំងបំណិនជីវិត គោលដៅជីវិត គោលដៅការងារ ដែលជួយដល់សិស្សានុសិស្សភាគច្រើនមានការអប់រំល្អ និងមានការងារធ្វើប្រកបដោយសុចន្ទៈដែលស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ខ្ញុំសង្ឃឹមថាអង្គការ ខេប នឹងបន្តជួយវិស័យអប់រំនៅកម្ពុជាសម្រាប់សិស្សដែលនឹងរៀនចប់ថ្នាក់ទី១២ ឱ្យសម្រេចបាន ៩០% សម្រាប់ជីវិតអ្នកសិក្សាទូទាំងប្រទេស"*។




# យថាគ្រោះណាស់បើកូនគ្មាន !

(បទពាក្យ៧)

១. បដិវត្តឧស្សាហកម្ម កូនធ្វើឧបកម្មសំសន្ទនា
ចាប់ពីទីមួយមកស្ទួនភ្ជា ឥឡូវត្រូវជាទីបួនហើយ។
២. វិវត្តឥតឈប់ទាំងយប់ថ្ងៃ ឱកែវចរណៃកុំកន្តើយ
កំណត់គោលដៅសម្លឹងត្រើយ កុំនៅតោះតើយភ្លេចស្មារតី។
៣. អាចសួរទីប្រឹក្សាអាជីព ផ្តល់ជាប្រទីបកូនប្រុសស្រី
តម្រែតម្រង់ឱ្យឃ្លាតខ្ចី បញ្ហារែងខ្លីសម្រាលធូរ។
៤. ចំណេះជំនាញប្រឹងស្វះស្វែង ឱហាតខ្នះខ្នែងខំគិតគូរ
វិភាគដោះស្រាយកុំនៅយូរ អត់ធ្មត់តស៊ូហើយទន់ភ្លន់។
៥. នវានុវត្តន៍បង្កើតថ្មី កែច្នៃទ្រឹស្តីជំនាញទន់
ឱ្យជាធនធានគួរគយគន់ ល្អល្អះលើសលន់ពន់ថ្លៃថ្លា។
៦. ព័ត៌មានវិទ្យាក៏ជាយាន កូនត្រូវតែមានជាប់អាត្មា
ទើបទាន់សម័យបម្រើការ នាយុគនេះណាពៅពិសី។
៧. គំនិតដឹកនាំដោះបញ្ហា ត្រិះរិះពិចារមានខន្តី
គ្រប់គ្រងអារម្មណ៍ពាក្យសម្តី ផ្តើមគំនិតថ្មីរៀបផែនការ។
៨. កូនមានឬនៅពៅស្ងួនអើយ ដល់ថ្ងៃនេះហើយមាសស្នេហា
មានគិតមានគូរពិចារណា ប្រុងប្រៀបកាយាបម្រុងទេ?
៩. យថាគ្រោះណាស់បើកូនគ្មាន បំណិនធនធាននេះមាសមេ
ដល់ថ្ងៃខាងមុខយើងចាញ់គេ កូនអើយរិះរេខិតខំទៅ។
១០.វាសនាជាតិយើងផ្ញើលើកូន សណ្តោងសណ្តូនគិតឱ្យជ្រៅ
យកជ័យឱ្យបានណាពាលពៅ នាំជាតិឆ្ពោះទៅរុងកិត្តិ។



និពន្ធដោយលោក **សំ មករា**
ជាគ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី
វិទ្យាល័យព្រះស៊ីសុវត្ថិ

**អ្នកត្រូវចេះឱ្យតម្លៃលើខ្លួនឯង កុំផ្ញើក្ដីសុខរបស់អ្នកលើមាត់អ្នកដទៃ។ ការខិតខំប្រឹងប្រែងរបស់អ្នកនៅថ្ងៃនេះ វាមិនហុចផលឱ្យភ្លាមៗទេ ប៉ុន្តែវាកំពុងដំណើរការទៅរកទិសដៅដែលអ្នកបានកំណត់ទុក។ ចូរអ្នកចងចាំថា មនុស្សម្នាក់ៗមានតម្លៃ និងចំនុចពិសេសរៀងៗខ្លួន។ ដូច្នេះ អ្នកត្រូវតែច្នៃខ្លួនឯងឱ្យមានតម្លៃចាប់ពីថ្ងៃនេះទៅ នោះអ្នកនឹងធ្វើរឿងណាដែលមានប្រយោជន៍ និងអាចជាជំហរជួយដល់អ្នកដទៃបាន។**